**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ឃួន សាមិត្ត**

**ញ៉ូ ប៊ុនឈុ**

សាស្ត្រាចារ្យណែនាំ

**លោក ញឹក ខុទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីរនាក់ឈ្មោះ **ឃួន សាមិត្ត** និង **ញ៉ំ ម៉ុនឈូ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០។

**យើងខ្ញុំសូមថ្លែងនូវកតញ្ញូតាធម៌ និងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះ៖**

- លោកឪពុក **ឋិន សុផល** និង អ្នកម្តាយ **នូ ម៉ៅ**
- លោកឪពុក **ញ៉ំ នឿក** និង អ្នកម្តាយ **សយ ចាន់**

សូមអរគុណដល់ លោកអ្នកមានគុណ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅ ណែនាំផ្តល់ដំបូន្មាន ព្រមទាំងផ្គត់ផ្គង់ជា ថវិកា សម្ភារៈប្រើប្រាស់ក្នុងការសិក្សា ផ្តល់ឲ្យគ្រប់យ៉ាងនូវកម្លាំងកាយ កម្លាំងចិត្តទាំង ផ្នែកបញ្ញា និងស្មារតី លើកទឹកចិត្ត ក្នុងការខិតខំសិក្សារៀនសូត្រ ក្រេបយកនូវចំណេះដឹងតាំងពីតូចក្រូចឆ្មារ រហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ គុណូបការៈ និងព្រហ្មវិហាធម៌របស់លោកអ្នកមានគុណចំពោះយើងខ្ញុំពិតជាមានទំហំធំធេងរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ទាំងនេះហើយដែលធ្វើឲ្យកូនមិនអាចបំភ្លេចបានហើយ គុណធម៌ និងព្រហ្មវិហាធម៌ទាំងនោះនឹងស្ថិតនៅក្នុងចិត្តកូនជានិច្ចដរាប។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំបានចូលសិក្សា និងផ្ទេរនូវចំណេះដឹង បទពិសោធន៍ ឯកសារ សិក្សាស្រាវជ្រាវ ដែលជាប្រទីបបំភ្លឺផ្លូវដល់យើងខ្ញុំក្នុងការសិក្សារៀនសូត្រកន្លងមក។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **លោកសាស្ត្រាចារ្យ ញឹក ឧុធ្ធី** ដែលលោកមិន ត្រឹមតែបានបង្រៀន ផ្តល់នូវចំណេះដឹងនោះទេ លោកថែមទាំងជា សាស្ត្រាចារ្យណែនាំ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់ការប្រឹក្សា និងអនុសាសន៍ល្អៗ ដែលធ្វើឲ្យកិច្ចដំណើរការនៃការស្រាវជ្រាវ និងចងក្រងនូវឯកសារសារណានេះប្រកបដោយ លទ្ធផលល្អនេះ។

សូមថ្លែងអំណរគុណជូនចំពោះ លោកតា លោកយាយ អ៊ុំប្រុស អ៊ុំស្រី លោកពូ អ្នកមីង បងប្អូន មិត្តភក្តិ និងសិស្សច្បង ទាំងអស់ ដែលបានផ្តល់ជាគំនិត និងកម្លាំងចិត្តដល់ យើងខ្ញុំក្នុងការសរសេរសារណានេះ។

ជាអវសាន យើងខ្ញុំសូមគោរពជូនពរ និងលើកហត្ថប្រួងសួងដល់គុណ ព្រះរតនត្រៃយ៍ គុណកែវទាំងបី អស់វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយតាមថែរក្សា **លោកឪពុក អ្នកម្តាយ ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ** ឲ្យជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជួបប្រកប តែសុខសួស្តីគ្រប់ប្រការកុំបីឃ្លាតកាយទៅជាបការៈដទៃឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាអស់រយៈពេល៤ឆ្នាំ ខាងជំនាញផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ខ្ញុំបាទទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សដែលសាកលវិទ្យាល័យបានផ្តល់ឱកាសដល់រូបខ្ញុំបាទទាំងពីរ បញ្ចេញនូវសមត្ថភាពខាងផ្នែកទ្រឹស្តីដែលបានសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះបាន សរសេរចងក្រងជាសារណាបញ្ចប់ការសិក្សាមួយនេះឡើង។ បន្ទាប់ពីបានខិតខំចំណាយពេលជាច្រើនក្នុងការក្រេបយកចំណេះវិជ្ជា ការសិក្សាស្រាវជ្រាវប្រមូលចងក្រងឯកសារ និងការទទួលបានបទពិសោធន៍ល្អៗ និងឯកសារមេរៀនដ៏មានអត្ថប្រយោជន៍ជាច្រើនបន្ថែមទៀតរបស់លោក - លោកស្រីសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀន ។ ខ្ញុំបាទទាំងពីរនាក់បានយល់ឃើញនូវមានចំណុចខ្វះខាតដែលពលរដ្ឋខ្មែរភាគច្រើនបានរៀបអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងបញ្ញត្តិច្បាប់ ដោយឪពុកម្តាយ ឬ សាមីជនខ្លួនឯងមួយចំនួនបានគិតតែប្រយោជន៍ដែលបានមកពីការរៀបអាពាហ៍ពិពាហ៍នោះជាធំ។

ដើម្បីចូលរួមចំណែកក្នុងការជួយសង្គម ខ្ញុំបាទទាំងពីរនាក់ ក៏បានស្រាវជ្រាវសារណាមួយដែលមានប្រធានបទស្តីពី "មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍" មកធ្វើជាកម្មវត្ថុក្នុងការស្រាវជ្រាវដើម្បីបញ្ចប់ឆ្នាំសិក្សានេះ។ ដើម្បីជួយឲ្យប្រជាពលរដ្ឋខ្មែរបានយល់ដឹងកាន់តែច្បាស់ អំពីសិទ្ធិរបស់ខ្លួនក្នុងការ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ ដែលផ្ទុយច្បាប់ឬ ដោយការបង្ខិតបង្ខំ ការបោកប្រាស់ផ្សេងៗតាមគ្រប់រូបភាព។ ក្នុងសារណាមួយច្បាប់នេះខ្ញុំបាទទាំងពីរនាក់ បានស្រាវជ្រាវ និងដកស្រង់ចេញពីឯកសារពាក់ព័ន្ធមួយចំនួនទាំងក្នុងបណ្ណាល័យក៏ដូចជាតាមប្រភេទឯកសារផ្សេងៗដែលអាចជួយជាគំនិត និងប្រាប់ពីចំណុចសំខាន់ដែលទាក់ទងនឹងប្រធានបទនេះ ។ ជាពិសេសខ្ញុំបាទទាំងពីរនាក់ក៏បានទទួលការណែនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកសាស្ត្រាចារ្យ ណែនាំ ដែលជាអ្នករៀបចំ ដឹកនាំក្នុងការស្វែងរកនូវឯកសារ ក៏ដូចជាការផ្តល់ជាគំនិតយោបល់ចំពោះប្រធានបទមួយនេះ។

ខ្ញុំបាទទាំងពីរនាក់ជឿកជាក់ថា អត្ថបទស្រាវជ្រាវនេះជាឯកសារមួយដ៏សំខាន់ ដែលវាអាចជំនួយដល់មិត្តអ្នកអាន ក្នុងការយល់ដឹងបន្ថែមពីចំណុចមួយចំនួនដែលទាក់ទង នឹងផ្នែករដ្ឋប្បវេណីជាពិសេសគឺ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍។ ប៉ុន្តែក្រោយពីធ្វើកិច្ចការនេះរួចខ្ញុំបាទទាំងពីរនាក់ក៏យល់បាន បន្ថែមមួយកំរិតទៀត ដែលអាចជួយឲ្យខ្ញុំទាំងពីរនាក់បានដើរទៅតាមអ្វីដែលច្បាប់បានបញ្ញត្តិចង្អុលបង្ហាញ និងបានស្វែងរកយល់ពីបញ្ញត្តិច្បាប់ដែលចែងទាក់ទងនឹងប្រធានបទនេះកាន់តែច្បាស់លាស់ថែមទៀតផង។ ជាទីបញ្ចប់ខ្ញុំបាទទាំងពីរនាក់ក៏សូមអភ័យទោសរាល់កំហុសខុសឆ្គងដែលអាចកើតមានឡើងក្នុងការសរសេរសារណានេះឡើង។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ..... **១**

១. លំនាំបញ្ហា ..... ១

២. ចំណោទបញ្ហា ..... ២

៣. គោលបំណង ..... ២

៤. ដែនកំណត់ និងវិសាលភាព ..... ៣

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ..... ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤

**ជំពូកទី១៖**

**ការបង្កើតអាពាហ៍ពិពាហ៍**

**ផ្នែកទី១៖ កំជាប់ពាក្យ** ..... **៥**

**កថាភាគទី១៖ ការបង្កើតកំជាប់ពាក្យ** ..... **៥**

១. ការចែចូវ ..... ៥

២. ការស្តីដណ្តឹង ..... ៥

៣. សេចក្តីសន្យា ..... ៦

៤. ពិធីកំជាប់ពាក្យ ..... ៧

**កថាភាគទី២៖ ការទទួលខុសត្រូវ** ..... **៧**

១. ការសងជំនូន ..... ៧

២. ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយពុំមានមូលហេតុត្រឹមត្រូវ ..... ៨

៣. នីតិវិធីដាក់ពាក្យបណ្តឹង ..... ៨

**ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍** ..... **៩**

**កថាភាគីទី១៖ និយមន័យ** ..... **៩**

**កថាភាគីទី២៖ លក្ខខណ្ឌទម្រង់** ..... **៩**

១. កិច្ចសន្យាអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយផ្ទាល់មាត់ ..... ៩

២. កិច្ចសន្យាអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយលាយលក្ខណ៍អក្សរ ........ ១០
**កថាភាគីទី៣៖ លក្ខខណ្ឌគ្រឹះ** ........ ១០
១. ការព្រមព្រៀង ........ ១១
១.១. ការព្រមព្រៀងរបស់គូស្រករ ........ ១១
១.២. ការព្រមព្រៀងរបស់ឳពុក-ម្ដាយ ........ ១១
២. អាយុ ........ ១១
២.១. លក្ខខណ្ឌទូទៅ ........ ១១
២.២. ករណីលើកលែង ........ ១២
២.៣. ការទទួលបានអគ្គាធីនភាព ........ ១២
២.៣.១. អនីតិជនមានអគ្គាធីនភាព និង អនីតិជនគ្មានអគ្គាធីនភាព ........ ១២
២.៣.២. នីតិជន និង អនីតិជន ........ ១៣
៣. ភេទផ្ទុយគ្នា ........ ១៣
៤. ភាពនៅលីវ ........ ១៤
៥. គោលការណ៍ឯកពន្ធភាព ........ ១៤
៦. វិធវភាព ........ ១៤
៧. ការហាមឃាត់រវាងញាតិលោហិត ........ ១៥
៨. ការហាមឃាត់រវាងញាតិពន្ធ ........ ១៥
៩. អាពាហ៍ពិពាហ៍ជននៅក្រោមអាណាព្យាបាលទូទៅ ........ ១៥

## ជំពូកទី២៖

## មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

**ផ្នែកទី១៖ មោឃភាពអាពាហ៍ពិពាហ៍** ........ ១៧
**កថាភាគទី១៖ មូលហេតុនៃមោឃភាព** ........ ១៧
១. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ........ ១៧
១.១. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុភាន់ច្រឡំលើមនុស្ស ........ ១៧
១.២. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយសារការបង្ខំ ........ ១៧
១.៣. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ដោយមូលហេតុផ្សេងទៀត ........ ១៨
២. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ........ ១៨

**កថាភាគទី២៖ នីតិវិធីនៃការបញ្ជាក់មោឃភាព** ...................... ១៩
១. អ្នកមានសិទ្ធិទាមទារឲ្យបញ្ជាក់អំពីមោឃភាព ...................... ២០
២. អាជ្ញាយុកាលនៃការប្ដឹងមោឃភាព ...................... ២១
**ផ្នែកទី២៖ ការលុបចោលអាពាហ៍ពិពាហ៍** ...................... ២១
**កថាភាគទី១៖ មូលហេតុការលុបចោល** ...................... ២១
១. មិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ...................... ២២
២. អាពាហ៍ពិពាហ៍ដែលជាប់សាច់ញាតិ ...................... ២២
២.១. ញាតិលោហិត ...................... ២២
២.២. ញាតិពន្ធ ...................... ២៣
៣. ទ្វេពន្ធភាព ...................... ២៣
៤. អាពាហ៍ពិពាហ៍អំឡុងពេលហាមឃាត់ ( ឬ ការមិនគោរពវិធវភាព ) ...................... ២៤
៥. អាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាម ...................... ២៤
**កថាភាគទី២៖ អាជ្ញាយុកាលនៃការប្ដឹងលុបចោល** ...................... ២៤
១. អាជ្ញាយុកាលកំណត់ដោយច្បាប់ ...................... ២៥
២. អាជ្ញាយុកាលដែលកើតឡើងដោយការបង្ហាញឆន្ទៈ ...................... ២៥
២.១. អាជ្ញាយុកាលស្ថិតក្នុងអំឡុងពេលហាមឃាត់ ...................... ២៥
២.២. អាជ្ញាយុកាលដោយការឆបោក ឬគំរាម ...................... ២៦
**កថាភាគទី៣៖ អ្នកមានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍** ...................... ២៦
១. ភាគីដែលរៀបអាពាហ៍ពិពាហ៍ ...................... ២៦
២. ញាតិសណ្ដានរបស់ភាគី ...................... ២៦
៣. តំណាងអយ្យការ ...................... ២៧
៤. ទ្វេពន្ធភាព ...................... ២៧
**កថាភាគទី៤៖ នីតិវិធីនៃការលុបចោលអាពាហ៍ពិពាហ៍** ...................... ២៧
១. សមត្ថកិច្ចតុលាការ ...................... ២៨
២. បណ្ដឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ ...................... ២៨
២.១. របៀបដាក់ពាក្យបណ្ដឹង ...................... ២៩
២.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង ...................... ២៩

៣. ការបង់ពន្ធប្រាក់ប្រដាប់ក្តី ........ ៣០
៣.១. ប្រភេទប្រាក់ប្រដាប់ក្តី ........ ៣០
៣.២. បន្ទុកនៃប្រាក់ប្រដាប់ក្តី ........ ៣១
៤. ការចាត់ចែងពាក្យបណ្តឹង ........ ៣១
៤.១. ការទទួលពាក្យបណ្តឹង ........ ៣១
៤.២. ការពិនិត្យពាក្យបណ្តឹង ........ ៣២
៤.៣. ការបញ្ជូនពាក្យបណ្តឹង ........ ៣២
៤.៤. ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ........ ៣៤
៥. នីតិវិធីនៃការត្រៀម និងទាញហេតុផលផ្ទាល់មាត់ ........ ៣៤
៥.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ........ ៣៥
៥.២. នីតិវិធីទាញហេតុផលផ្ទាល់មាត់ ........ ៣៥
៥.២.១. ការជម្រះក្តីក្នុងការទាញហេតុផលផ្ទាល់មាត់ ........ ៣៦
៥.២.២. ការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ........ ៣៧
៦. សេចក្តីសម្រេចលើបណ្តឹង ........ ៣៧
៦.១. សាលក្រមចំពោះមុខ ........ ៣៧
៦.២. បណ្តឹងឧបាស្រ័យ ........ ៣៨

## ជំពូកទី៣៖

## អានុភាពនៃមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

**ផ្នែកទី១៖ អានុភាពនៃមោឃភាព** ........ ៣៩
**កថាភាគទី១៖ អានុភាពចំពោះទំនាក់ទំនងញាតិ** ........ ៣៩
**កថាភាគទី២៖ អានុភាពចំពោះបុគ្គល** ........ ៣៩
១. ចំពោះសាមីជន ........ ៣៩
២. ចំពោះទំនាក់ទំនងនឹងកូន ........ ៣៩
២.១. ការសន្មតបិតុភាព ........ ៤០
២.២. អំណាចមេបា (ទោល) ........ ៤០
២.៣. សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន ........ ៤០
៣. ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច ........ ៤០

**កថាភាគទី៣៖ អានុភាពចំពោះទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ....... ៤១**
៣.១. ទ្រព្យសម្បត្តិដោយឡែក ....... ៤១
៣.២. ទ្រព្យសម្បត្តិរួម ....... ៤២
**ផ្នែកទី១៖ អានុភាពនៃការលុបចោល ....... ៤២**
**កថាភាគទី១៖ អានុភាពចំពោះសំណងការខូចខាត ....... ៤២**
**កថាភាគទី២៖ អានុភាពចំពោះបុគ្គល ....... ៤៣**
១. ចំពោះសាមីជន ....... ៤៣
២. ចំពោះបុត្តភាព ....... ៤៣
៣. ការមិនផ្តល់អាហារកិច្ច ....... ៤៤
**កថាភាគទី៣៖ អានុភាពចំពោះទ្រព្យសម្បត្តិរបស់សហព័ទ្ធ ....... ៤៤**
១. ប្រព័ន្ធទ្រព្យសម្បត្តិតាមវិធាននៃកិច្ចសន្យា ....... ៤៤
២. ប្រព័ន្ធទ្រព្យសម្បត្តិកំណត់តាមច្បាប់ ....... ៤៥
២.១. ទ្រព្យសម្បត្តិដោយឡែក ....... ៤៥
២.២. ទ្រព្យសម្បត្តិរួម ....... ៤៥
**សេចក្តីសន្និដ្ឋាន ....... ៤៧**
**អនុសាសន៍ ....... ៤៨**
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ការគោរពនិងប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ទៅនឹងប្រពៃណីទំនៀមទម្លាប់ក្នុងការប្រារព្ធនូវពិធីផ្សេងៗ ដោយក្នុងនោះផងដែរក៏មាន ពិធីរៀបអាពាហ៍ពិពាហ៍ដែល គ្រប់គ្នានិយមហៅថាការរៀបមង្គលការ។ ពីបុរាណកាលមក មុននឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍ គឺមានពិធីរៀបចំជាច្រើនដំណាក់កាលផ្សេងៗគ្នា។ ក្នុងនោះដែរមានដូចជា ពិធីចែចូវចូលស្តីដណ្តឹង ពិធីភ្ជាប់ពាក្យ ឬកំជាប់ពាក្យទើបឈានចូលដល់ពិធីរៀបអាពាហ៍ពិពាហ៍ ដោយពិធីទាំងអស់នេះធ្វើឡើងផ្សេងៗគ្នា ទៅតាមតំបន់ ឬ លទ្ធភាពរបស់គ្រួសារនីមួយៗផង។ ប៉ុន្តែទោះបីជាមានពិធីតាមប្រពៃណី យ៉ាងនេះក្តីក៏អាពាហ៍ពិពាហ៍នោះ មិនត្រូវបានច្បាប់ចាត់ទុកថាជាអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវ តាមច្បាប់កំណត់នោះទេ។

អាពាហ៍ពិពាហ៍ គឺជាទំនាក់ទំនងសង្គម រវាងសមាជិកគ្រួសារ ប្តីនិងប្រពន្ធកូនៗនិងឪពុកម្តាយ ឬរវាងបណ្តាលបុគ្គល ផ្សេងទៀតដែលជាសមាជិកនៃគ្រួសារទាំងសងខាង ។ ម្យ៉ាងវិញទៀតក៏អាច និយាយបានថា អាពាហ៍ពិពាហ៍ គឺជាមូលដ្ឋានរបស់គ្រួសារ ពីព្រោះថាបុរសនិងស្ត្រី ដែលបានជ្រើសរើសគ្នាធ្វើជាគូស្វាមីភរិយាសុទ្ធសឹងតែមានគោលបំណងក្នុងការកសាងគ្រួសារសម្រាប់រស់នៅក្នុងសង្គមមួយ ជាមួយគ្រួសារដ៏ពេញលេញនិងមានសុភមង្គលមួយតាមចិត្តប្រាថ្នា។ អាពាហ៍ពិពាហ៍ ក៏ជាចំណងមនោសញ្ចេតនា រវាងបុរស និងស្ត្រីពីរនាក់ដោយផ្អែកលើមូលដ្ឋានស្ម័គ្រចិត្ត និងសមភាព ហើយត្រូវបានច្បាប់ទទួលស្គាល់ពីគោលបំណង ក្នុងការកសាងគ្រួសាររបស់ខ្លួន ដោយការព្រមព្រៀង ប្រកបដោយសុភមង្គលផង។ បើតាមបញ្ញាត្តិច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារបាន និយមន័យអាពាហ៍ពិពាហ៍ ថាជាកិច្ចសន្យាឱឡារិកមួយដែលធ្វើឡើងដោយ បុរស និងស្ត្រីម្នាក់ដែលប្តេជ្ញាចិត្តថាខ្លួន នឹងរួមសមគ្គសង្វាសគ្នា តាមរយៈបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយ វិញទៅតាមទំនើងចិត្តរបស់ខ្លួនឡើយ។

ចំណងអាពាហ៍ពិពិពាហ៍ កើតឡើងដោយសារ ស្ម័គ្រចិត្តរវាងបុរស និងស្ត្រីដោយខ្លួនឯង គឺវាឆ្លុះបញ្ចាំងនូវគោលការណ៍សំដែងឆន្ទៈ ដោយឈរលើទស្សនៈនៃសេរីភាពស្វ័យសម្រេចលើការរើសគូស្រករ ដោយស្របតាមបញ្ញត្តិច្បាប់ដោយគ្មានការបង្ខិតបង្ខំពីសំណាក់បុគ្គលណាម្នាក់ដូចជា ឪពុកម្តាយ បងប្អូនសាច់ញាតិ ។ ចំពោះអាពាហ៍ពិពាហ៍ ដែលបានបង្កើតឡើងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ គឺនឹងមិនបាត់បង់ សុពលភាពយោងតាមច្បាប់ថ្មីបច្ចុប្បន្នឡើយ ដោយសន្មតថាមុននូវសុពលភាពនៃអាពាហ៍ពិពាហ៍ដែលត្រូវបានបង្កើតឡើង តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩។

រៀបអាពាហ៍ពិពាហ៍ បានលុះត្រាតែ មានភេទផ្ទុយគ្នា ហើយបានដល់នីតិភាព មានន័យថា អាយុ១៨ ឆ្នាំយ៉ាងតិច។ ប៉ុន្តែជនដែលមាន អាយុ១៦ឆ្នាំឬ១៧ឆ្នាំ ក៏អាចរៀបអាពាហ៍ពិពាហ៍បានដែរ ដោយសារជននោះ

ទទួលបានអត្តាធីនភាព។ ម្យ៉ាងទៀត ប្រសិនបើភាគីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ ដោយមានភាគីម្ខាងជាអនីតិជន រៀបអាពាហ៍ពិពាហ៍ នឹងអាចប្រព្រឹត្តទៅបានដោយគ្រាន់តែមានការអនុញ្ញាតពី ឪពុកម្តាយ ឬ អាណាព្យាបាលរបស់អនីតិជននោះ។ ប៉ុន្តែប្រសិនបើឪពុកម្តាយឬ អាណាព្យាបាលសម្រាប់ អនីតិជននោះ បដិសេធមិនយល់ស្របចំពោះអាពាហ៍ពិពាហ៍នោះ សាមីជនមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីច្រានចោលការបដិសេធនោះបានហើយតុលាការ នឹងពិនិត្យសម្រេចគាំទ្រ ឬ មិនគាំទ្រការជំទាស់របស់អ្នកមានសិទ្ធិអំណាចមេបាលើភាគីអនីតិជននោះក្រោយពីការស្តាប់ការបំភ្លឺរបស់អាណាព្យាបាល។

ដោយព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ឯកពន្ធភាពឆ្នាំ២០០៦ ដោយក្នុងនោះបានកំណត់ថា បុគ្គលដែលមានសហព័ទ្ធហើយ មិនអាចរៀបអាពាហ៍ពិពាហ៍ទៀតបានទេ។ ដូច្នេះការបំពានលក្ខខណ្ឌនេះនឹងនាំមកឲ្យមានការទាមទារឲ្យលុបចោលស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុង មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ ដោយឡែកចំពោះបុគ្គល ដែលបានបាត់ខ្លួនបន្ទាប់ពីបានស្នើសុំតុលាការស្តីពីការប្រកាសអំពី ការបាត់ខ្លួនរួចរាល់ សហព័ទ្ធម្ខាងទៀតនឹងអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតជាមួយបុគ្គលម្នាក់ទៀតបាន។ ក្រោយការរំលាយនូវចំណងអាពាហ៍ពិពាហ៍ ជាគោលការណ៍នារី នឹងអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយត្រូវស្ថិតក្នុងវិធវភាព (ភាពជាស្ត្រីមេម៉ាយ) រយៈពេល១២០ថ្ងៃគិតចាប់ពីអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ។ ភាគីនៃអាពាហ៍ពិពាហ៍ ត្រូវតែមិនមែនជាញាតិលោហិតខ្សែផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផង។

ជារួមមូលហេតុនៃមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ជាកម្មវត្ថុចម្បង នៃសារណាដែលក្នុងនោះនឹងត្រូវសិក្សាបង្ហាញទៅលើបញ្ហាមួយចំនួន។

## ២. ចំណោទបញ្ហា

ជារួមមូលហេតុនៃមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ជាកម្មវត្ថុចម្បង នៃសារណាដែលក្នុងនោះនឹងត្រូវសិក្សាបង្ហាញទៅលើបញ្ហាមួយជាអាទិ៍៖

១.តើមូលហេតុអ្វីបណ្តាលឲ្យមាន មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍?

២.តើមានបុគ្គលណាខ្លះដែលមានសិទ្ធិស្នើសុំទាមទារឲ្យមោឃភាពនិងការលុបចោលអាពាហ៍ពិពាហ៍?

៣.តើមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ នឹងជួបផលវិបាកក្នុងការអនុវត្តយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណង

ការធ្វើការសិក្សាស្រាវជ្រាវសារណានេះ មានគោលបំណង សិក្សាស្វែងយល់ឲ្យច្បាស់អំពីហេតុផលនានាក្នុងសង្គមកម្ពុជាដែលនាំឲ្យកើតមានឡើងនូវ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ក្នុងគ្រួសារនីមួយៗនៅក្នុងកម្ពុជា និងរកឲ្យឃើញនូវមូលហេតុ វិជ្ជមាន អវិជ្ជមានដែលជាឧបសគ្គក្នុងការ ប្តឹងតវ៉ាឲ្យ

មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ ដែលកើតឡើងហើយផ្ទុយពីបទបញ្ញត្តិ និងវិសាលភាពនៃច្បាប់កំណត់។ ការសិក្សាអំពី " មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ " នេះជាគោលបំណងដែលចង់សិក្សាពង្រឹងបន្ថែម លើសមត្ថភាពនៃចំណេះដឹងចំពោះប្រធានបទមួយនេះ ឲ្យបានកាន់តែស៊ីជម្រៅនឹងជឿជាក់ថាអាចយកទៅប្រើប្រាស់ក្នុងសង្គមជាពិសេសនៅក្នុង មូលដ្ឋានដែលរស់នៅ នឹងផ្សព្វផ្សាយជាលក្ខណៈគ្រួសារ ឬចូលរួមការងារស្ម័គ្រចិត្ត ជាមួយយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងច្បាប់ក្នុងវិស័យអាពាហ៍ពិពាហ៍ ឲ្យប្រជាពលរដ្ឋជាពិសេសបុគ្គលដែលមានវ័យអាចរៀបអាពាហ៍ពិពាហ៍បាន យល់ដឹងអំពីសិទ្ធិសេរីភាពរបស់ខ្លួនក្នុងការរៀបចំគូជីវិតស្របតាមឆន្ទៈនិង បញ្ញត្តិច្បាប់ជាធរមាន មិនត្រឹមតែប៉ុណ្ណោះសារណាមួយច្បាប់នេះ ក៏ចូលរួមចំណែកយ៉ាងសំខាន់សម្រាប់និស្សិតសិក្សាស្រាវជ្រាវទាំងឡាយណាដែល បានអាននូវខ្លឹមសារទាំងមូល សម្រាប់ជាទុនផ្នែកគំនិតបញ្ញានិងស្មារតីផងដែរ។

### ៤. ដែនកំណត់ និងវិសាលភាព

ការស្រាវជ្រាវសារណា "មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍" គឺជាការសិក្សាស្រាវជ្រាវ និងស្វែងរកពីមូលហេតុដែលនាំឲ្យមានការមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។ ដែនកំណត់នៃការសិក្សាស្រាវជ្រាវសារណានេះ និយាយតែពីអាពាហ៍-ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ ហើយអនុលោមទៅតាមច្បាប់កម្ពុជា ដែលបានចែងនៅក្នុង ក្រមរដ្ឋ-ប្បវេណី ឆ្នាំ២០០៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨២ ច្បាប់ស្តីពីឯកពន្ធភាព ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងបណ្តាប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធើណែត(Internet) ជាច្រើន ផ្សេងទៀត។ វិសាលភាពនៃការស្រាវជ្រាវសារណាមួយច្បាប់នេះ គឺផ្តោតយ៉ាងខ្លាំងហើយសំខាន់ សម្រាប់ការប្រើប្រាស់ប្រព័ន្ធយុត្តាធិការនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

### ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទណាមួយ គឺពិតជាមានការលំបាកណាស់ ព្រោះត្រូវការចំណាយពេលវេលាច្រើន ចំណាយកម្លាំងកាយចិត្ត ក៏ដូចជាថវិកាជាដើម ជាពិសេស គឺត្រូវមានចំណង់ចំណូលចិត្ត និងការព្យាយាម បន្ថែមទៀតផងដែរ ទើបការសិក្សាស្រាវជ្រាវទទួលបានជោគជ័យ។

ទោះបីមានការលំបាកយ៉ាងណាក៏ដោយ ក៏នៅតែខិតខំជម្នះឲ្យទាល់តែបាន ពីព្រោះថា ការសិក្សាស្រាវជ្រាវ ប្រធានបទនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដែលក្នុងនោះរួមមានដូចជា៖

- ទទួលបានចំណេះដឹងថ្មីៗ ពាក់ព័ន្ធនឹងវិធីស្រាវជ្រាវ
- ទទួលបានប្រភពឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ
- យល់ដឹងកាន់តែលម្អិតទៅលើប្រធានបទ ដែលបានសិក្សាស្រាវជ្រាវ

- ចេះធ្វើការប្រៀបធៀបរវាងចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយ
- ធ្វើឲ្យកាន់តែច្បាប់បន្ថែមទៀត អំពីការរៀបប្រយោគ ឃ្លោងឃ្លា អក្ខរាវិរុទ្ធ
- ទទួលបានបទពិសោធន៍ល្អៗ ពីអ្នកមានចំណេះដឹង និងព្រមទាំងអ្នកមានបទពិសោធន៍
- ពិសេស គឺបានបន្សល់ស្នាដៃទុកសម្រាប់សិស្ស និស្សិត បានសិក្សាស្រាវជ្រាវបន្តទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ ទៅលើសារណាថ្នាក់បរិញ្ញាបត្រនេះ ធ្វើឡើងស្របទៅតាមលក្ខណៈវិទ្យាសាស្ត្រ និង ស្របទៅតាមនីតិវិធីគោលការណ៍នៃការសរសេរសារណា របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យា-សាស្ត្រសេដ្ឋកិច្ច ហើយការស្រាវជ្រាវស្វែងរកឯកសារ ផ្សេងៗទៀតតាមរយៈអ៊ីនធើណែត នៅក្នុងបណ្ណាល័យ ច្បាប់បណ្ណាល័យជាតិ ជាពិសេសទទួលមតិណែនាំសំខាន់ៗពី សំណាក់ មិត្តភក្តិ សិស្សច្បង លោកគ្រូសាស្ត្រា-ចារ្យដឹកនាំសារណានេះ ក៏ដូចជាសាស្ត្រាចារ្យផ្សេងៗទៀតជាច្រើនផង ដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាមួយនេះបានស្រាវជ្រាវឡើង និងចងក្រងជាភាសាខ្មែរដែលក្នុងនោះចែកចេញជា ៣ជំពូករួម មាន៖

ជំពូកទី១៖ ការបង្កើតអាពាហ៍ពិពាហ៍

ផ្នែកទី១៖ កំជាប់ពាក្យ

ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

ជំពូកទី២៖ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

ផ្នែកទី១៖ មោឃភាពអាពាហ៍ពិពាហ៍

ផ្នែកទី២៖ ការលុបចោលអាពាហ៍ពិពាហ៍

ជំពូកទី៣៖ អានុភាពនៃមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

ផ្នែកទី១៖ អានុភាពនៃមោឃភាព

ផ្នែកទី២៖ អានុភាពនៃការលុបចោល

# ជំពូកទី១៖
# ការបង្កើតអាពាហ៍ពិពាហ៍

## ផ្នែកទី១៖ កំជាប់ពាក្យ

"កំជាប់ពាក្យ"[1] ត្រូវបង្កើតតាមសេចក្តីសន្យាដែលបុរស និង នារីបានព្រមព្រៀងគ្នាថានឹងរៀបអាពាហ៍ពិពាហ៍ រវាងគ្នានាពេលអនាគត ដោយសន្យាធ្វើពិធីកំជាប់ពាក្យ។ ដោយហេតុថា ការសន្យានេះហើយទើបធ្វើអោយបុរស និង នារី ត្រូវធ្វើពិធីកំជាប់ពាក្យ ដើម្បីបញ្ជាក់ថាអ្នកទាំងពីរជាគូនឹងគ្នា ហើយដើម្បីប្រកាសប្រាប់មនុស្សទាំងអស់គ្នាថា បុរសនោះ និង នារីនោះមានម្ចាស់ហើយ។

### កថាភាគទី១៖ ការបង្កើតកំជាប់ពាក្យ

កំជាប់ពាក្យ គឺជាពិធីមួយដែលគេធ្វើឡើងនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ដើម្បីជាសញ្ញាណមួយបញ្ជាក់ថាបុរស ឬ នារីនោះមានគូកំណាន់នឹងម្ចាស់ចិត្តរួមហើយ។ លើសពីនេះទៅទៀតវាក៏ជា លក្ខខណ្ឌមួយសម្រាប់គ្រួសារទាំងពីរ ដែលមានន័យថាពួកគេបានភ្ជាប់សាច់ឈាម នឹងគ្នាហើយដោយសារពិធីកំជាប់ពាក្យនេះ។ ម៉្យាងវិញទៀតការបង្កើតកំជាប់ពាក្យ ត្រូវកើតឡើងទៅតាមផ្លូវច្បាប់ដោយមានការព្រមព្រៀងពីភាគីខាងកូនប្រុស និង ភាគី ខាងកូនស្រីមុនពេលរៀបអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់។ បើយោងទៅតាមសម័យបុរាណ ការបង្កើតពិធីកំជាប់ពាក្យនេះគេត្រូវធ្វើឡើងតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

**១. ការចែចូវ**

ជាទូទៅការចែចូវ គឺគេធ្វើឡើងនៅពេលដែលមាតាបិតាខាងកូនប្រុសបានមើលឃើញកូនស្រីរបស់នរណាម្នាក់ ឬ ពេញចិត្តនឹងកូនស្រីនរណាម្នាក់ដោយចង់បានធ្វើជាកូនប្រសារនោះ គាត់និងពឹងពាក់អ្នកដែលមានមុខមាត់ មានគេគោរពច្រើនក្នុងភូមិ (អ្នកផ្លូវ) ដើម្បីចូលស៊ើបសួរពីមាតាបិតាខាងកូនស្រី ថាកូនរបស់គាត់នៅទំនេរ ឬមួយក៏អត់ទាន់មានគូ។ ការចូលចែចូវនេះគេធ្វើឡើងបីលើកគឺ៖

លើកទី១ អ្នកផ្លូវចូលទៅសួរសុខទុក្ខធម្មតាដោយគ្មានកាន់អ្វីនៅក្នុងដៃទៅជាមួយទេ។ លើកទី២ អ្នកផ្លូវចូលទៅដៃទទេដដែល តែចូលទៅម្តងនេះគឺដើម្បីស្ទង់មើលចិត្តថ្លើមមាតាបិតាខាងកូនស្រីប៉ុណ្ណោះ។ លើកទី៣ នៅពេល ដែលបានដឹងថាមានសង្ឃឹមហើយថាមាតាបិតាខាងកូនស្រីយល់ព្រមហើយ នោះអ្នកផ្លូវត្រូវចូលទៅម្តងទៀតដោយ ម្តងនេះត្រូវកាន់នៅរបស់ជាប់ដៃទៅជាមួយផងដែលរួមមាន បារី ម្លូស្លា ដាក់ក្នុងពានយកទៅជាមួយផង។

**២. ការស្តីដណ្តឹង**

[1] មាត្រា៩៤៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នៅពេលចូលស្ដីដណ្ដឹងមាតាបិតាខាងប្រុសរកអ្នកមុខ អ្នកការ មានហោរបីនាក់ ឲ្យធ្វើជាអ្នកផ្លូវចូលទៅស្ដីដណ្ដឹងកូនស្រី ដោយមានរបស់កំដរដៃដូចការចូលចែចូវ ដែលមាន ម្លូ ស្លា បារី ស្លាបផ្កា កំបោរ កាន់មកជាប់ដៃជាមួយផង។ ចំពោះការស្ដីដណ្ដឹងក៏មាន ៣ដំណាក់កាលដូចគ្នាទៅនិងការចែចូវដែរ ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្ននេះ គឺគេធ្វើតែមួយដំណាក់កាលជាការស្រេច។ ចំពោះដំណាក់កាលនៅសម័យបុរាណនៃការស្ដីដណ្ដឹងរួមមាន៖

លើកទី១ អ្នកផ្លូវត្រូវជម្រាបទៅមេបាជាពាក្យយ៉ាងនេះថា "សូមទាន សូមជម្រាបអស់លោកមេបាតូចធំត្រកូលរៀមច្បង សូមទានជ្រាប ដ្បិត ពឹងពរអ្នកទាំង៣នាក់ ឲ្យធ្វើជាអ្នកផ្លូវ នាំភស្តុភារ បណ្ណាការមកជូនលោកមេបា សុំស្គាល់ សុំស្រឡាញ់ជាសម្ព័ន្ធមិត្តនឹង លោកមេបា ឈ្មោះនាង.........ថានៅទំនេរឥតមានទាក់ទាងសម្ដីនឹងអ្នកណាទេ ឬដូចម្ដេច? ពេលនោះមេបាខាងស្រីនឹងឆ្លើយតបមកវិញថាឲ្យឬមិនឲ្យ"។[2]

លើកទី២ អ្នកផ្លូវ ចូលទៅដូចមុន ហើយនិយាយ "......ដ្បិតដើងមុន អ្នកសុំឲ្យលោកមេបាដោះពាក្យដែលជំពាក់នោះ ឥឡូវនេះលោកបានដោះរួចហើយ ឬនៅ[3]?

លើកទី៣ "អ្នកផ្លូវសុំស្ដីដណ្ដឹងម្ដងទៀត តែមេបាតូច (មេបាស្រី) ឆ្លើយថាស្រេចលើមេបាធំ (មេបាប្រុស)"[4]។ ប៉ុន្តែសម្រាប់បច្ចុប្បន្ននេះពិធីមួយចំនួនក៏ត្រូវបានកាត់ចោលផងដែរ ដោយសារតែចំណាយពេលវេលាយូរចំណែក ឯការចំណាយថវិការក៏ច្រើន។ ចំពោះពិធីចែចូវ និង ស្ដីដណ្ដឹងក៏ត្រូវបានកាត់ចេញនៅពិធីមួយចំនួនផងដែរដែល បច្ចុប្បន្ននេះការចូលចែចូវគឺមានតែមួយលើកប៉ុណ្ណោះ ហើយយកជាការតែម្ដង។ ចំពោះការស្ដីដណ្ដឹងវិញក៏ដូចគ្នាដែរ ឲ្យតែកូនប្រុសស្រីបានព្រមព្រៀងគ្នា ហើយមានការយល់ព្រមឪពុកម្ដាយសងខាងនោះគឺអាចប្រារព្ធពិធីបានដូចគ្នា ដែលភាគច្រើនគេធ្វើតែមួយលើជាការស្រេច។ ម្យ៉ាងវិញទៀត វាចំណេញពេល និងថវិកាសម្រាប់គ្រួសារទាំងពីរផងដែរ។

### ៣. សេចក្ដីសន្យា

សេចក្ដីសន្យា គឺសំដៅលើភាគីទាំងពីរដែលជាបុរស នារី បានបង្ហាញឆន្ទៈនៃការព្រមព្រៀងថានឹងយកគ្នាជា ប្ដី ប្រពន្ធ ស្របតាមច្បាប់។ ម្យ៉ាងវិញទៀត សេចក្ដីសន្យានេះនឹងឈានទៅរកការរៀបអាពាហ៍ពិពាហ៍នាពេលអនាគតផងដែរ។ បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា៩៤៤ ក៏បានចែងផងដែរថា "កំជាប់ពាក្យត្រូវបង្កើតឡើង តាមសេចក្ដីសន្យារវាងបុរស នារីថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានាពេលអនាគត និង ដោយធ្វើ

[2] វិគីភីឌា, ០៣ មិថុនា ២០១៥, Km.wikipedia.org.com
[3] វិគីភីឌា, ០៣ មិថុនា ២០១៥, Km.wikipedia.org.com
[4] វិគីភីឌា, ០៣ មិថុនា ២០១៥, Km.wikipedia.org.com

ពិធីកំជាប់ពាក្យ[5]”។

ដូចនេះ សេចក្តីសន្យា គឺជាការព្រមព្រៀងរវាងបុរស និង នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានៅពេលអនាគត ដោយឆ្លងកាត់នៅពិធីកំជាប់ពាក្យ។

**៤. ពិធីកំជាប់ពាក្យ**

“ពិធីកំជាប់ពាក្យ ឬ ការលើកស្លា ឬ ការនិយាយភាសាដែលប្រជាជនខ្មែរធ្លាប់ហៅប្រចាំថ្ងៃថា (ការភ្ជាប់ពាក្យ)។ ពិធីកំជាប់ពាក្យ ជាប្រពៃណីដែលមានតាំងពីបុរាណណាស់មកហើយ ហើយក៏ជាពិធីធំមួយមុន នឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ នៅសព្វថ្ងៃនេះ ពិធីនៅមានការនិយមជាទូទៅ មុននឹងកូនបុត្រធីតារបស់ពួកគេឈានទៅដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ហើយនៅក្នុងគ្រួសារដែលមានជីវភាពធូរធារបានរៀបចំពិធីនេះយ៉ាងអធិកអធមធំប៉ុនគ្នា នឹងពិធីរៀបអាពាហ៍ពិពាហ៍ដែរ ប៉ុន្តែសម្រាប់គ្រួសារដែលមានជីវភាពមធ្យម បានរៀបចំតូចល្មមទៅតាមធនធាន ហើយសម្រាប់អ្នកខ្លះដែលមានជីវភាពមិនធូរធាន បានលើកពិធីនេះចោលក៏មានដែរ។ ពិធីនេះគេច្រើនធ្វើមួយព្រឹក ឬ ពេញមួយថ្ងៃតែម្តង ហើយមានការបំពាក់ចិញ្ចៀន ឬខ្សែក ឬក៏ប្រគល់វត្ថុអនុស្សាវរីយ៍ ផ្សេងៗដល់អនាគតស្វាមី ឬភរិយាទៀតផង តាមការនិយម និង តាមសមត្ថភាពធនធានដែលភាគីមាន”[6]។

កំជាប់ពាក្យៈ សំដៅដល់ ពិធីតាមទំនៀមទម្លាប់ប្រពៃណីដែលច្បាប់ទទួលស្គាល់ ដែលតាមរយៈពិធីនេះ បុរស និង នារី សន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។

**កថាភាគទី២៖ ការទទួលខុសត្រូវ**

នៅក្នុងពិធីកំជាប់ពាក្យ នៅពេលណាដែលមានបញ្ហាណាមួយកើតឡើងដែលនាំឲ្យឈានទៅដល់ការលុបចោលនៅពិធីកំជាប់ពាក្យ នោះភាគីដែលធ្វើខុសត្រូវទទួលខុសត្រូវចំពោះភាគីម្ខាងទៀត។ ចំពោះករណីដែលអាច រំលាយពិធីកំជាប់ពាក្យនេះទៅគឺមានមូលហេតុដូចខាងក្រោមនេះ៖

រំលាយដោយអាពាហ៍ពិពាហ៍ រំលាយដោយមរណភាពរបស់ភាគីណាមួយ រំលាយដោយការព្រមព្រៀងរបស់ភាគី រំលាយដោយការបដិសេធចោលដោយមានមូលហេតុត្រឹមត្រូវ រំលាយដោយការបដិសេធដោយគ្មានមូលហេតុត្រឹមត្រូវ។

**១. ការសងជំនូន**

ប្រទេសកម្ពុជាក៏ដូចជាប្រទេសមួយចំនួនដែរ តាមទំនៀមទម្លាប់មានករណីជាច្រើនដែលការជូនដល់ភាគីម្ខាងទៀតនូវប្រាក់កាស និងទ្រព្យ (ជំនូន) ត្រូវបានធ្វើឡើងនៅពេលដែលមានគម្រោងរៀបអាពាហ៍ពិពាហ៍

[5] មាត្រា៩៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[6] គន ឌឿន. ២០១៣. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រ ២០-២១។

ជាពិសេស ភាគីម្ខាង "អាចទាមទារអោយភាគីម្ខាងទៀតសងជំនូនមកវិញ"[7] បានក្នុងករណីដែលកំជាប់ពាក្យត្រូវបានរំលាយ។ ផ្ទុយទៅវិញ នៅពេលដែលភាគីដែលបានភ្ជាប់ពាក្យ ហើយបានរៀបអាពាហ៍ពិពាហ៍រួមហើយនោះ ភាគីមិនអាចទាមទារឲ្យសងជំនូននោះពីភាគីម្ខាងទៀតបានទេ នោះបីជាពួកគេបានលែងលះក៏ដោយ។ ការសងនៅជំនូន គឺត្រូវធ្វើឡើងនៅកំឡុងពេលដែលមានកំជាប់ពាក្យ ដែលមានដូចជាប្រាក់សម្រាប់ការជួលទីកន្លែងសម្រាប់រៀបចំពិធី ឬ ថ្លៃ របស់របរផ្សេងៗទៀតដែលបានរៀបចំពិធីនោះ។ ការសងសំណងនេះអាចកើតមានឡើងលុះត្រាតែកម្មវិធីនោះបាន ប្រារព្ធឡើង ទើបភាគីដែលខូចខាចមានសិទ្ធិក្នុងការទាមទារសំណងនេះមានន័យថា ប្រសិនបើពិធីកំជាប់ពាក្យបាន បញ្ចប់មុនពេលកម្មវិធី (រៀបចំពិធី ជួលទីកន្លែង ឬ របស់របបផ្សេងៗនៅក្នុងពិធី) ម៉្យាងមិនបានធ្វើឲ្យប៉ះពាល់ដល់ ភាគីម្ខាងទៀតនោះមិនត្រូវទទួលខុសចំពោះសំណងនោះទេ។

ការទទួលខុសត្រូវក្នុងការសងជំនូននេះ កើតឡើងដោយមិនគិតពីមូលហេតុនៃការរំលាយកំជាប់ពាក្យទេ លើកលែងតែការរំលាយដោយអាពាហ៍ពិពាហ៍។ ដូចនេះ ទោះបីជាកំជាប់ពាក្យត្រូវបានរំលាយដោយមរណៈភាព របស់ភាគីណាមួយក្តី ដោយការព្រមព្រៀងរបស់គូភាគីក្តី ឬដោយសារបដិសេធចោលដោយមូលហេតុត្រឹមត្រូវក្តី ក៏ភាគីត្រូវសងជំនូននោះវិញដែរ។

### ២. ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយពុំមានមូលហេតុត្រឹមត្រូវ

កំជាប់ពាក្យគឺជាដំណើរការសង្គម ដែលជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយមានអត្ថន័យតាមផ្លូវច្បាប់លើសពីពិធីដែលគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ។ ក្នុងករណីដែលភាគីម្ខាងបដិសេធកំជាប់ពាក្យចោលដោយមិនត្រឹមត្រូវភាគីនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតមានន័យថា "ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងពីការបដិសេធនោះបាន"[8] ។ មូលហេតុត្រឹមត្រូវរួមមានភាពស្មោះត្រង់របស់ ភាគីម្ខាងទៀតអំពើហិង្សាតាមរយៈពាក្យសំដី ឬលើរូបរាងកាយ ឬអសមត្ថភាពផ្លូវកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។ ការខូចខាតក្នុងចំណុចនេះរួមមាន ការខូចខាតផ្នែកផ្លូវចិត្តក៏ដូចជាការខូចខាតផ្នែកទ្រព្យសម្បត្តិ ដូចជាការចំណាយប្រាក់សម្រាប់កក់ភោជនីដ្ឋានសម្រាប់រៀបចំកម្មវិធីរៀបអាពាហ៍ពិពាហ៍ ឬ ការចំណាយផ្សេងៗទៀតដែលធ្វើឡើងនៅ ពេលរៀបអាពាហ៍ពិពាហ៍។

### ៣. នីតិវិធីដាក់ពាក្យបណ្តឹង

នៅពេលដែលកំជាប់ពាក្យត្រូវបានរំលាយ ឬ បដិសេធចោលដោយគ្មានមូលហេតុត្រឹមត្រូវភាគីម្ខាងទៀតមានសិទ្ធិធ្វើការប្តឹងទាមទារទៅតុលាការទាមទារសំណង ដូចជាការសងជំនូន ការទទួលខុសត្រូវផ្សេងៗ

[7] មាត្រា៩៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[8] មាត្រា៩៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទៀតដោយភាគីនោះ "ត្រូវប្តឹងទៅតុលាការនៅក្នុងអំឡុងពេល ១ (មួយ)ឆ្នាំគិតចាប់ពីពេលដែលកំដាប់ពាក្យនោះបានរលាយ"[9]។ ប្រសិនបើហួសនៅអំឡុងពេលមួយឆ្នាំនោះការប្តឹងទាមទារសំណងនោះនឹងមិនអាចធ្វើបាននោះទេគឺអាស្រ័យទៅ លើភាគីដែលបានព្រមព្រៀងគ្នាវិញ។

## ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

### កថាភាគីទី១៖ និយមន័យ

បើយោងទៅតាមនិយមន័យនៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩ បានកំណត់និយមន័យថា "អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាមួយដែលធ្វើឡើងដោយបុរសម្នាក់ និង នារីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ដែលមិនអាចរំលាយបានតាមទំនើងចិត្តខ្លួនបានឡើយ"[10]។ ទោះបីជាច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩ បានចែងនិយមន័យដូចខាងលើមែនតែច្បាប់នេះបាននិរាករណ៍បាត់ទៅហើយ។

ប៉ុន្តែ បើយោងទៅតាមក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ មិនបានកំណត់និយមន័យនៃអាពាហ៍ពិពាហ៍នេះនៅឡើយនោះទេ។ ដោយសារតែមិនមានការកំណត់និយមន័យនៅក្នុងក្រមរដ្ឋប្បវេណីបែបនេះហើយ ទើបធ្វើឲ្យគេពឹងផ្អែកទៅលើច្បាប់អាពាហ៍ពិពាហ៍ចាស់។

ម៉្យាងវិញទៀតដើម្បីឲ្យចំណងអាពាហ៍ពិពាហ៍មួយអាចប្រព្រឹត្តទៅបានលុះត្រាតែ គោរពនូវលក្ខខណ្ឌពីរ គឺលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់។ លក្ខខណ្ឌទាំងពីរនេះតម្រូវឲ្យមានជាចាំបាច់នៅក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍។

### កថាភាគីទី២៖ លក្ខខណ្ឌទម្រង់

លក្ខខណ្ឌទម្រង់ គឺជាលក្ខខណ្ឌមួយដែលនាំឲ្យបង្កើតនៅចំណងអាពាហ៍ពិពាហ៍ផងដែរ។ នៅក្នុងលក្ខខណ្ឌទម្រង់នេះ គឺ លក្ខខណ្ឌដែលបានធ្វើឡើងដោយគូភាគីដែលចង់រៀបអាពាហ៍ពិពាហ៍បានព្រមព្រៀងគ្នា ហើយការព្រមព្រៀងនេះអាចធ្វើឡើងដោយផ្ទាល់មាត់ និង ជាលាយល័ក្ខណ៍អក្សរទៅតាមការសន្យារបស់គូភាគីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍នោះ។

#### ១. កិច្ចសន្យាអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយផ្ទាល់មាត់

នៅក្នុងសង្គមកម្ពុជា ការរៀបអាពាហ៍ពិពាហ៍គឺ ត្រូវធ្វើឡើងទៅតាមទំនៀមទម្លាប់ ប្រពៃណីសាសនាដែលមានទាំងពីរបុរាណមកម្ល៉េះ។ ដោយហេតុនេះចំពោះការសន្យាដោយផ្ទាល់មាត់នៅក្នុងរឿងអាពាហ៍ពិពាហ៍

[9] មាត្រា៩៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[10] មាត្រា៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

នោះពុំមាននោះទេ ហើយប្រសិនបើមានការសន្យាបែបនេះក៏មាននៅក្នុងពិធីប៉ុណ្ណោះ ។ ម៉្យាងវិញទៀតនៅក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក៏មិនបានចែងអំពីកិច្ចសន្យាអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយផ្ទាល់មាត់នេះដែរ។ ដូចនេះចំពោះការសន្យាបែបនេះនឹងមិនមានអានុភាពឡើយចំពោះផ្លូវច្បាប់។

**២. កិច្ចសន្យាអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយលាយល័ក្ខណ៍អក្សរ**

កិច្ចសន្យា គឺជាការព្រមព្រៀងដែលមានការបង្ហាញនៅឆន្ទៈក្នុងការបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ចអ្វីមួយដែលបានព្រមព្រៀងក្នុងកិច្ចសន្យា។ នៅក្នុងកិច្ចសន្យា គឺចាំបាច់ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដែលមានការព្រមព្រៀងរបស់គូភាគីក្នុងការបង្កើត។ ចំពោះកិច្ចសន្យាអាពាហ៍ពិពាហ៍ក៏ដូចគ្នាផងដែរ គឺត្រូវបង្កើតឡើងជាលាយល័ក្ខណ៍អក្សរ ទើបធ្វើឲ្យកិច្ចសន្យានោះមាន អានុភាពគតិយុត្តិទៅតាមផ្លូវច្បាប់បាន។ មានន័យថា អាពាហ៍ពិពាហ៍ក៏ជាកិច្ចសន្យាមួយដែរ ព្រោះថាបើយោងតាមនិយមន័យនៃកិច្ចសន្យាក៏បានបញ្ញត្តិផងដែរថា "កិច្ចសន្យាគឺជាកិរិយា ដែលបុគ្គលពីរនាក់ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬ រំលត់នូវកាតព្វកិច្ច"[11]។ ចំណុចនេះបង្ហាញថា អាពាហ៍ពិពាហ៍គឺការសន្យាមួយដែលស្ថិតនៅក្នុងកិច្ចសន្យា ព្រោះនៅពេលបង្កើតចំណងអាពាហ៍ពិពាហ៍គឺត្រូវមាន ការព្រមព្រៀងគ្នាដែលមានការបង្ហាញឆន្ទៈរបស់កូនកំលោះ និងកូនក្រមុំ ព្រមទាំងគ្រួសារទាំងសងខាងផងដែរ។

ដូចនេះ ដើម្បីឲ្យកិច្ចសន្យាមួយមានសុពលភាព គូភាគី (ប្ដី ប្រពន្ធ) ត្រូវតែមានការព្រមព្រៀងគ្នាក្នុងការបង្កើតនៅចំណងអាពាហ៍ពិពាហ៍ដោយមិនមានការ បង្ខិតបង្ខំ ឬ ការកុហកបោកប្រាស់ដើម្បីផលចំណេញណាមួយឡើយ។ លើសពីនេះទៅទៀតនោះ កិច្ចសន្យាអាពាហ៍ពិពាហ៍នេះ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរដោយមានការយល់ព្រមពីសំណាក់ប្ដីប្រពន្ធផងដែរ។ ការធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរបែបនេះគឺដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវការសន្យារវាងបុរស និង នារីឬ រវាងក្រុមគ្រួសាររបស់អ្នកទាំងពីរមុនឈានដល់ការរៀបអាពាហ៍ពិពាហ៍របស់កូនប្រុស ស្រី ដើម្បីក្លាយជាប្ដីប្រពន្ធនឹងគ្នា។ ការធ្វើបែបនេះក៏មានអានុភាពចំពោះផ្លូវច្បាប់ផងដែរ មានន័យថា ការធ្វើកិច្ចសន្យាអាពាហ៍ពិពាហ៍ជាលាយល័ក្ខណ៍អក្សរនោះត្រូវបានផ្លូវច្បាប់ទទួលស្គាល់ព្រោះជាភស្តុតាងដ៏សំខាន់ នៅពេលដែលនាំឲ្យមានការអនុវត្តន៍កិច្ចសន្យា។

**កថាភាគីទី៣៖ លក្ខខណ្ឌគ្រឹះ**

លក្ខខណ្ឌគ្រឹះ គឺជាលក្ខខណ្ឌចំបងដែលធ្វើអោយកើតមានចំណងអាពាហ៍ពិពាហ៍ ដែលប្ដីប្រពន្ធគ្រប់រូបត្រូវតែប្រតិបត្តិឲ្យខានតែបាន ពីព្រោះអាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពជីវិតគូរវាងបុរស និងនារី។ ដូចនេះ បុរស និងនារី ចាំបាច់ត្រូវតែពេញវ័យទាំងផ្នែកសេដ្ឋកិច្ច សង្គម ផ្លូវចិត្ត និងផ្លូវកាយ ហើយវាគឺជាការកំណត់តាមច្បាប់

[11] មាត្រា៣១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ជាពិសេស នោះគឺជាលក្ខខណ្ឌដែលទាមទារឲ្យមានការគោរពនូវលក្ខខណ្ឌចំបងមួយចំនួនគឺ៖

**១. ការព្រមព្រៀង**

“បុរស និងនារីដែលមានអាយុពេញលេញលក្ខណៈច្បាប់ មានសិទ្ធិពេញលេញក្នុងការសម្រេចរៀបអាពាហ៍ពិពាហ៍។ ភាគីម្ខាងមិនអាចបង្ខំភាគីម្ខាងទៀតបានឡើយ”[12]។ ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយអាចបង្កើតទៅបាននោះ ចាំបាច់ត្រូវតែមានការព្រមព្រៀងរវាងគូភាគី ក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ ដោយមិនមានការបង្ខិតបង្ខំពីមជ្ឈដ្ឋានណាមួយឡើយ ហើយចំពោះការព្រមព្រៀងទាំងនោះឃើញមានការព្រមព្រៀងរបស់គូស្រករជាដើម។

**១.១. ការព្រមព្រៀងរបស់គូស្រករ**

អាពាហ៍ពិពាហ៍ ត្រូវគោរពតាមគោលការណ៍ស្ម័គ្រចិត្ត មានការព្រមព្រៀងរវាងគូស្រករ។ ប្រសិន“បើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍បានកើតឡើង ដោយសារ ការភាន់ច្រឡំ លើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងទៀតនោះអាពាហ៍ពិពាហ៍នោះត្រូវចាត់ទុកជាមោឃៈ”[13]។

**១.២. ការព្រមព្រៀងរបស់ឪពុក-ម្តាយ**

បើយោងទៅតាមការចុះស្រាវជ្រាវឯកសារនៅសាលាសង្កាត់ទឹកថ្លាវិញ ចៅសង្កាត់ទឹកថ្លាបានពន្យល់ប្រាប់មកថាអាពាហ៍ពិពាហ៍ ចាំបាច់ត្រូវតែមានការយល់ព្រមពីសំណាក់ឪពុកម្តាយទាំងសងខាង។

ប៉ុន្តែបើយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧មិនបានចែងអំពីការយល់ព្រមពីសំណាក់ឪពុកម្តាយទេនោះមានន័យថា ទោះបីជាមិនមានការយល់ព្រមពីសំណាក់ឪពុកម្តាយទាំងសងខាងក៏ដោយ ក៏កូនប្រុសស្រីនៅតែអាចរៀបអាពាហ៍ពិពាហ៍បានដដែល ដោយហេតុថានៅក្នុងក្រមរដ្ឋប្បវេណីមិនបានហាមឃាត់ទាក់ទង នឹងបញ្ហាទាំងនេះទេ។

**២. អាយុ**

**២.១. លក្ខខ័ណ្ឌទូទៅ**

“បុរស នារី ដែលមិនទាន់ចម្រើនវ័យដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានឈានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ ឆ្នាំអាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ”[14]។

[12] មាត្រា៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

[13] មាត្រា៩៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[14] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឧទាហរណ៍ៈ ស្រីនី មានអាយុ ១៦ឆ្នាំហើយ នាងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយ កុសល ដែលមានអាយុ ២០ឆ្នាំ។ ក្នុងករណីនេះ ដែលមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ដោយសារតែស្រីនី ស្ថិតក្នុងវ័យជាអនីតិជននៅឡើយ។ ប៉ុន្តែក្នុងករណីពិសេស អាចរៀបអាពាហ៍ពិពាហ៍បាន ដោយសារ អ្នកមានអំណាចមេបា ឬ អាណាព្យាបាលរបស់នាងបានយល់ព្រម។

**២.២. ករណីលើកលែង**

បើទោះជាច្បាប់បានបញ្ញត្តិអំពីលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ ក៏នៅតែមានករណីមួយចំនួនអាចធ្វើការលើកលែងផងដែរ។ ករណីលើកលែងក្នុងការរៀបអាពាហ៍ពិពាហ៍នេះ បុរស នារី ត្រូវបានទទួលអត្តាធីនភាព ក្លាយខ្លួនជានីតិជន ដែលជាជនដែលមានសមត្ថភាពហើយច្បាប់ទទួលស្គាល់។ ចំពោះការទទួលបានអត្តាធីនភាពនេះ មិនមែនសុទ្ធតែអាចទទួលបាននោះទេ គឺត្រូវគោរពទៅតាមលក្ខខណ្ឌដែលច្បាប់កំណត់។ មានន័យថា ការទទួលបានអត្តាធីនភាព គឺតុលាការជាអ្នកសម្រេចសេចក្តីថា បុគ្គលនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាច ទទួលបានអត្តាធីនភាព ឬ ក៏មិនអាច។

**២.៣. ការទទួលបានអត្តាធីនភាព**

ការទទួលបានអត្តាធីនភាពរបស់អនីតិជន គឺច្បាប់ទទួលស្គាល់ថាបុគ្គលនោះមានសមត្ថភាពដូចនីតិជន។ ចំពោះ "អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព"[15] នេះបើយោងតាមមាត្រា២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

**២.៣.១. អនីតិជនមានអត្តាធីនភាព និង អនីតិជនគ្មានអត្តាធីនភាព**

ចំពោះអនីតិជនដែលមិនទាន់គ្រប់អាយុ ១៨ឆ្នាំ អាចស្នើសុំអត្តាធីនភាពបានតាមរយៈតុលាការ។ បើយោងទៅតាមមាត្រា ២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ កថាខណ្ឌទី១ បានចែងថា "ក្នុងករណីដែលអនីតិដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នក នោះបានតាមពាក្យស្នើសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថាអត្តាធីនភាពស្របនឹងផលប្រយោជន៍ របស់អនីតិជននោះ។ នៅក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា"[16]។

ដូចនេះ ចំពោះអនីតិជន និង អនីតិជន ក៏អាចរៀបអាពាហ៍ពិពាហ៍បានផងដែរ ឲ្យតែទទួលបាននៅអត្តាធីនភាពពីតុលាការ។

---

[15] មាត្រា២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[16] មាត្រា២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ២.៣.២. នីតិជន និង អនីតិជន

ការរៀបអាពាហ៍ពិពាហ៍ គឺត្រូវធ្វើឡើងដោយបុរស និង នារី ដែលមានវ័យឈានដល់នីតិភាព។ ប៉ុន្តែនៅក្នុងករណីនេះ ក៏មានការលើកលែងផងដែរ ប្រសិនបើ "ភាគីម្ខាងឈានដល់នីតិភាពហើយភាគីម្ខាងទៀតជាអនីតិជន ដែលមានអាយុមិនតិចជាង ១៦ ឆ្នាំនោះគឺអាចរៀបអាពាហ៍ពិពាហ៍បាន ដោយមានការយល់ព្រមពីអ្នកដែលមាន អំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ"[17]។

ម៉្យាងវិញទៀត នៅពេលដែល "អនីតិជនបានរៀបអាពាហ៍ពិពាហ៍ហើយនោះ នឹងត្រូវទទួលបាននូវអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ"[18]។ ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនអាចទទួលបានអត្តាធីនភាពនេះដោយស្វ័យប្រវត្តិ ទោះបីជានៅពេលដែលមានការលែងលះគ្នា ក៏អានុភាពនៃអត្តាធីនភាពនេះមិនរលត់ដែរ។

ឧទាហរណ៍: មេសា មានអាយុ ២០ឆ្នាំ និង នាង លីសា អាយុ ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានប៉ុន្តែត្រូវតែមានការយល់ព្រមពីអំណាចមេបា ឬ អាណាព្យាបាលរបស់អនីតិជន។ នៅពេលដែល នាង លីសា បានរៀបអាពាហ៍ពិពាហ៍ហើយនោះនឹងទទួលបាននៅអត្តាធីនភាពដោយស្វ័យប្រវត្តិ ដោយមិនបាច់ស្នើសុំទៅតុលាការនោះទេ។

### ៣. ភេទផ្ទុយគ្នា

ច្បាប់បានកំណត់អំពីអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលត្រូវធ្វើឡើងរវាងមនុស្សដែលមានភេទផ្ទុយគ្នា។ បើយោងតាមការកំណត់របស់ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារឆ្នាំ ១៩៨៩ ក៏បានកំណត់ដែលថា អាពាហ៍ពិពាហ៍ត្រូវ ធ្វើឡើងស្របតាមលក្ខខ័ណ្ឌការស្ម័គ្រចិត្តរវាងបុរសម្នាក់ និងនារីម្នាក់។ នៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារក៏ កំណត់ផងដែរ អំពីលក្ខខណ្ឌនៃការហាមមិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទដូចគ្នា។ ចំណែកឯ បើយោងតាមមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នា ២០០៧វិញ ក៏បានបញ្ជាក់ផងដែរថាបុរស និង នារី មានន័យថាអ្នក រៀបអាពាហ៍ពិពាហ៍គឺត្រូវតែជាមនុស្សមានភេទផ្ទុយគ្នា។ ម៉្យាងវិញទៀត នៅក្នុងប្រទេសកម្ពុជាក៏មិនទាន់មានច្បាប់ ទទួលស្គាល់នូវការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នានៅឡើយទេ។

ដូចនេះ ការរៀបអាពាហ៍ពិពាហ៍ គឺចាំបាច់ត្រូវធ្វើឡើងជាមួយបុរសម្នាក់ និង នារីម្នាក់ដែលមានភេទផ្ទុយគ្នាទើបស្របទៅតាមផ្លូវច្បាប់។ ក្នុងករណីដែល មានការរៀបអាពាហ៍ពិពាហ៍ជាមួយភេទដូចគ្នានោះ គេចាត់ទុកថាជា អំពើខុសច្បាប់ ហើយអាចធ្វើអោយប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណី ដ៏ល្អរបស់ខ្មែរផងដែរ។

---

[17] មាត្រា៩៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[18] មាត្រា២១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**៤. ភាពនៅលីវ**

ការបង្កើតចំណងអាពាហ៍ពិពាហ៍ទៅបានលុះត្រាតែ បុរស ឬ នារីទាំងនោះនៅលីវ។ មានន័យថា បុរស ស្ត្រី ទាំងនោះមិនទាន់រៀបអាពាហ៍ពិពាហ៍ ឬ បានកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ចាស់រួចហើយ។ ក្នុងករណីអ្នកដែល បានរៀបអាពាហ៍ពិពាហ៍រួចហើយតែមានគោលបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយ ភាគីផ្សេងទៀត លុះត្រាតែ អាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់ ព្រមទាំងត្រូវបានច្បាប់ទទួលស្គាល់ថាអាពាហ៍ពិពាហ៍នោះបានបញ្ចប់ពិតមែន និង ដឹងលឺជាសាធារណៈផងដែរ។ នៅក្នុងប្រទេសកម្ពុជាក៏បានកំណត់ផងដែរថា "បុរស ត្រូវតែមានប្រពន្ធមួយ ឯស្ត្រីមានប្តីតែមួយ"[19] នេះបើយោងច្បាប់ទ្វេពន្ធភាព នៃព្រះរាជាណាចក្រកម្ពុជា។

**៥. គោលការណ៍ឯកពន្ធភាព**

ប្រសិនបើមានបុរស ឬ នារីណា ដែលមិនទាន់បានបញ្ចប់នៅអាពាហ៍ពិពាហ៍ចាស់ នោះច្បាប់មិនអនុញ្ញាត ឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីនោះទេ ហើយប្រសិនបើមាននោះ គេចាត់ទុកថាជាអំពើផិតក្បត់ ហើយច្បាប់នឹងមិនអនុញ្ញាត ឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីនោះទេ ដែលល្មើសទៅនឹងច្បាប់ឯកពន្ធភាព។ បើយោងតាមមាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី បានចែងថា "បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ"[20]។

ហេតុនេះ ប្រសិនបើភាគីណាដែលចង់រៀបអាពាហ៍ពិពាហ៍ថ្មី នោះចាំបាច់ត្រូវតែបញ្ចប់អាពាហ៍ពិពាហ៍ចាស់សិនទើបមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ថ្មី បើមិនដូច្នោះនឹងផ្ទុយទៅនឹងច្បាប់ឯកពន្ធភាព។

**៦. វិធវភាព**

ចំពោះវិធវភាពនេះផងដែរ គឺធ្វើឡើងចំពោះតែនារីនោះទេ ចំណែកឯបុរសមិនត្រូវបានហាមឃាត់នោះឡើយក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មី នៅពេលដែលអាពាហ៍ពិពាហ៍នោះបានរំលាយ ឬ បានធ្វើការលែងលះហើយនោះ។ បុរសអាចរៀបអាពាហ៍ពិពាហ៍ថ្មីនៅពេលណាក៏បាន ឲ្យតែអាពាហ៍ពិពាហ៍ចាស់នោះបានបញ្ចប់។ ប៉ុន្តែចំពោះនារី ត្រូវតែរងចាំវិធវភាពនេះ ព្រោះថាការធ្វើបែបនេះគឺដើម្បីឲ្យដឹងថាកូននៅក្នុងផ្ទៃរបស់នារី នោះជាកូនរបស់ប្តីមុន ឬ ជាកូនរបស់ប្តីក្រោយ។

បើទោះបីក្រមរដ្ឋប្បវេណីបានចែងអញ្ចឹងមែន តែដោយសារសម័យបច្ចុប្បន្ននេះបច្ចេកវិទ្យាទំនើប នោះគេមិនចាំបាច់រងចាំដល់ ១២០ថ្ងៃនោះទេនៅក្នុង "ករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជបណ្ឌិត"[21]។ នៅក្នុងករណីនេះនារី គឺអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយមិនចាំបាច់រងចាំរហូតដល់ ១២០ថ្ងៃដូចក្នុងក្រម

---

[19] មាត្រា៣ នៃច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ២០០៦។

[20] មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[21] មាត្រា៩៥០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បានចែងនោះទេ។

### ៧. ការហាមឃាត់រវាងញាតិលោហិត

រាល់អាពាហ៍ពិពាហ៍ទាំងអស់មិនមែនសុទ្ធតែ ត្រូវបានច្បាប់ទទួលស្គាល់នោះទេ ដោយហេតុថា អាពាហ៍ពិពាហ៍ទាំងត្រូវបានច្បាប់ហាមឃាត់ ។ ដែលក្នុងនោះការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតក៏ត្រូវបានច្បាប់ហាមឃាត់ដែរ។ លើសពីនេះទៅទៀត នៅក្នុងក្រមរដ្ឋប្បវេណីក៏មានចែងអំពីការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ រវាងញាតិលោហិតនេះដែរ។ ហើយបើយោងតាមមាត្រា៩៥១នៃក្រមនេះដដែលក៏បានចែងដែលថា"អាពាហ៍ពិពាហ៍ មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុង ៣ (បី) ថ្នាក់រាប់ទាំង ថ្នាក់ទី ៣ (បី) ផង"[22]។ ដែលនេះបង្ហាញឲ្យឃើញថាការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតបែបនេះ គឺត្រូវបានច្បាប់ហាមឃាត់ ម៉្យាងទៀតផ្ទុយទៅនឹងសីលធម៌សង្គមក៏ដូចជាទំនៀមទម្លាប់ ប្រពៃណីដ៏ល្អរបស់ខ្មែរផង។

### ៨. ការហាមឃាត់រវាងញាតិពន្ធ

ការហាមឃាត់ចំពោះការរៀបអាពាហ៍ពិពាហ៍មិនមែនត្រឹមតែញាតិលោហិតនោះ ចំពោះញាតិពន្ធក៏ត្រូវបានច្បាប់ហាមឃាត់ដែរ ព្រោះការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ មានទំនាក់ទំនងប្រហាក់ប្រហែលនឹង ញាតិលោហិតខ្សែផ្ទាល់របស់ខ្លួនដែរ។ លើសពីនេះទៅទៀតបើយោងតាមក្រមរដ្ឋប្បវេណី ២០០៧ បានចែងថា "អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធខ្សែផ្ទាល់"[23]។ ម៉្យាងវិញទៀតអាពាហ៍ពិពាហ៍ត្រូវហាមឃាត់ផងដែរ "រវាងសាខាញាតិពន្ធ នៅក្នុង ៣ ថ្នាក់រាប់ទាំងថ្នាក់ទី៣ ផង"[24]។

ចំណុចនេះបង្ហាញឲ្យឃើញថា ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ គឺជាអាពាហ៍ពិពាហ៍មួយដែលច្បាប់ហាមឃាត់។ ប្រសិនបើមានភាគីណាបានរៀបអាពាហ៍ពិពាហ៍ជាមួយញាតិពន្ធនោះ គឺជាអំពើល្មើសច្បាប់ ហើយច្បាប់ក៏មិនទទួលស្គាល់ផងដែរ។

### ៩. អាពាហ៍ពិពាហ៍ជននៅក្រោមអាណាព្យាបាលទូទៅ

ជនវិកលចរិក ឬ ភាសាច្បាប់ហៅថាជនវិប្បល្លាស្មារតី ឬ ជននៅក្រោមអាណាព្យាបាលទូទៅដែលជានីតិជន ប៉ុន្តែច្បាប់នៅប្រទេសកម្ពុជាក៏អនុញ្ញាតឲ្យជនប្រភេទនេះ អាចរៀបអាពាហ៍ពិពាហ៍បានដែរ ប្រសិនបើជននេះមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈចង់រៀបអាពាហ៍ពិពាហ៍ក្នុងកម្រិតអប្បរិមាដែលគេអាចទទួលយកបាន។ អាពាហ៍ពិពាហ៍ អាចប្រព្រឹត្តទៅបានដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ ដែល

[22] មាត្រា៩៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[23] មាត្រា៩៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[24] មាត្រា៩៥២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

គ្រប់គ្រងជនវិកលចរិកនោះទេ។ បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក៏បញ្ញត្តិបានផងដែរថា ការរៀបអាពាហ៍ពិពាហ៍របស់ "ជននៅក្រោមអាណាព្យាបាលទូទៅ អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈក្នុង កម្រិតអប្បរិមា។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ"[25]។

ឧទាហរណ៍ៈ លោក ក ជាជនវិកលចរិក ប៉ុន្តែគាត់ចង់រៀបអាពាហ៍ពិពាហ៍ជាមួយ នាង ខ ដោយអ្នកទាំងពីរអះអាងថានឹងរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះ អ្នកទាំងពីរអាចរៀបអាពាហ៍ពិពាហ៍ ដោយការបង្ហាញឆន្ទៈថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន។ ដូចនេះ អ្នកទាំងពីរអាចរៀបអាពាហ៍ពិពាហ៍បាន ដោយពុំចាំបាច់មានការយល់ព្រមពីអាណាព្យាបាលទូទៅឡើយ។

[25] មាត្រា៩៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ជំពូកទី២៖
# មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

## ផ្នែកទី១៖ មោឃភាពអាពាហ៍ពិពាហ៍

### កថាភាគទី១៖ មូលហេតុនៃមោឃភាព

"អាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកជាមោឃៈ ក្នុងករណីដែលភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែបានរៀបអាពាហ៍ពិពាហ៍ ដោយសារការភាន់ច្រឡំលើមនុស្ស ឬ មានការបង្ខំ ឬមូលហេតុផ្សេងទៀត[26]"។

"អាពាហ៍ពិពាហ៍ ត្រូវចាត់ទុកជាមោឃៈផងដែរ ក្នុងករណីភាគីមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពុំបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជាអាទិ៍ ឬមានកំហុសនីតិវិធីក្នុងការចុះបញ្ជីអាពាហ៍ពិពាហ៍ លើកលែងតែកំហុសនីតិវិធីបន្តិចបន្តួច[27]"។

#### ១. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍

#### ១.១. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុភាន់ច្រឡំលើមនុស្ស

ភាគីរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយសារតែមានការភាន់ច្រឡំលើមនុស្ស ( ភាគីរៀបអាពាហ៍-ពិពាហ៍ ) ហេតុនេះប្រសិនបើ បានដឹងថា បុគ្គលដែលខ្លួននឹងរៀបអាពាហ៍ពិពាហ៍ជាមួយ មិនមែនមនុស្សដែលខ្លួនចង់រៀបជាមួយទេ ខ្លួននឹងមិនរៀបអាពាហ៍ពិពាហ៍ទេ[28]។

ឧទាហរណ៍ "ក" បានចាប់ចិត្តស្រលាញ់ "ខ" ហើយចង់រៀបការជាមួយនឹង "ខ" ប៉ុន្តែ "ក" បានបង្កើតអាពាហ៍ពិពាហ៍ជាមួយ "គ" ដោយគិតថា "គ" គឺជា "ខ" ក្នុងករណីនេះ "ក" គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍នឹង "គ" ទេអាពាហ៍ពិពាហ៍ ត្រូវបានបង្កើតឡើយដោយការភាន់ច្រឡំ។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាង "ក" និង "គ" ត្រូវចាត់ទុកជា មោឃៈ ដោយមូលហេតុ "ក" គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

#### ១.២. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយសារការបង្ខំ

ការបង្ខំ គឺជាស្ថានភាពបុគ្គលដែលត្រូវបានគេបង្ខំ មិនបានបង្ហាញឆន្ទៈរៀបអាពាហ៍ពិពាហ៍ (គ្មានឱកាស ក្នុងការបង្ហាញឆន្ទៈ) ប៉ុន្តែអាពាហ៍ពិពាហ៍ ត្រូវបានបង្កើតឡើងដោយសារស្ថានភាពនៃការបង្ខំនោះ ក្នុងករណីនេះ អាពាហ៍ពិពាហ៍នោះ ត្រូវបានចាត់ទុកជាមោឃៈ[29]។

---

[26] មាត្រា៩៥៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[27] មាត្រា៩៥៨ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[28] មាត្រា៩៥៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[29] មាត្រា៩៥៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឧទាហរណ៍ "ក" ចង់រៀបការជាមួយ "ខ" ប៉ុន្តែ "ខ" មិនចង់រៀបការជាមួយ "ក" ទេ ម្តាយរបស់ "ខ" តែងតែធ្វើបាប គម្រាមកំហែងនាងគ្រប់បែបយ៉ាងបន្ទាប់មក "ក" បានបង្ខំ "ខ" ឲ្យចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ដោយចាប់ដៃរបស់ "ខ" ឲ្យចុះហត្ថលេខា នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ហើយ "ក" បានប្រាប់មន្ត្រីអត្រានុកូលដ្ឋានថា "ខ" កំពុងខឹងទើបមិនព្រមចុះហត្ថលេខា (មនុស្សស្រី ង ង៉ក់ច្រើន) បន្តិចទៀតទៅនឹងបាត់ខឹងហើយ។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាង "ក" និង "ខ" ត្រូវចាត់ទុកជា មោឃៈដោយមូលហេតុ "ខ" គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

### ១.៣. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ដោយមូលហេតុផ្សេងទៀត

ក្រៅពីការបង្ខំ ឬ ភាន់ច្រឡំលើភាគីនៃអាពាហ៍ពិពាហ៍ មូលហេតុផ្សេងទៀតត្រូវបានចាត់ទុកថាជា មូលហេតុនៃមោឃភាពអាពាហ៍ពិពាហ៍ដូចជាករណី រៀបការដើម្បីទទួលបានសញ្ជាតិជាដើម[30]។

ឧទាហរណ៍ "ក" ដោយសារចង់បានសញ្ជាតិ ដើម្បីអាចរស់នៅបរទេស ក៏បង្កើតអាពាហ៍ពិពាហ៍ជាមួយ "ខ" ខណៈពេលដែល "ក" មាន "គ" ជាសង្សា ហើយបានគិតថា ក្រោយពីបានសញ្ជាតិ នឹងលែងលះជាមួយ "ខ" ។ ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាង "ក" និង "ខ" ត្រូវចាត់ទុកជា មោឃៈ ដោយមូលហេតុ "ក" គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

### ២. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍

ក្នុងករណី ភាគីមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជូនដំណឹងជាសាធារណៈចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍នេះត្រូវទុកជាមោឃៈ[31]។

ឧទាហរណ៍១ "ក" និង "ខ" រួមរស់ជាមួយគ្នាដូចប្តីប្រពន្ធ "ក" ចង់ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តែម្នាក់ឯង ហើយចុងក្រោយ មន្ត្រីអត្រានុកូលដ្ឋានបានចុះឈ្មោះ "ក" និង "ខ" ជាប្តីប្រពន្ធស្របច្បាប់ក្នុងបញ្ជីអាពាហ៍ពិពាហ៍ដោយគ្មានហត្ថលេខារបស់ "ខ" ទេ។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាង "ក" និង "ខ" ត្រូវចាត់ទុកជាមោឃៈ ដោយមូលហេតុ "ខ" មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជាអាទិ៍ហេតុនេះ មិនទទួលស្គាល់ការចុះឈ្មោះរបស់ "ខ" នៅក្នុងបញ្ជីអាពាហ៍-ពិពាហ៍។

[30] មាត្រា៩៥៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[31] មាត្រា៩៥៨ ចំណុច ខ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឧទាហរណ៍ទី២ "ក" និង "ខ" រួមរស់ជាមួយគ្នាដូចប្តីប្រពន្ធ អ្នកទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍-ពិពាហ៍ ប៉ុន្តែមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងចុះបញ្ជីអាពាហ៍ពិពាហ៍នោះទេ។

ក្នុងករណីនេះ លក្ខខណ្ឌក្នុងការរៀបអាពាហ៍ពិពាហ៍មិនត្រូវបានបំពេញឡើយ មានន័យថា "ក" និង "ខ" មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពួកគេមិនបានបំពេញនីតិវិធីរហូតដល់មានការចុះបញ្ជីអាពាហ៍ពិពាហ៍ឡើយ ហេតុនេះគ្មានការបង្កើតអាពាហ៍ពិពាហ៍រវាង "ក" និង "ខ" ទេ ។ តាមបញ្ញត្តិនៃមាត្រា៩៥៨ ចំណុច "ខ" វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ករណីនេះត្រូវបានចាត់ទុកជាមោឃៈផងដែរ។

កំណត់សំគាល់៖ អនីតិសង្វាស ភាគីមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពុំមាន ឆន្ទៈចុះបញ្ជីអាពាហ៍-ពិពាហ៍ទេ បើផ្អែកតាមមាត្រា៩៥៨ ចំណុច "ខ" គឺជាមូលហេតុនៃមោឃភាព[32]។ ការលើកចំណុចស្តីពីមោឃ-ភាពចំពោះស្ថានភាពអនីតិសង្វាស ពុំមានផលប្រយោជន៍ទេ ពីព្រោះអនីតិសង្វាស ជាប្រព័ន្ធមួយដាច់ដោយឡែកពីអាពាហ៍ពិពាហ៍ ឬ មោឃភាពអាពាហ៍ពិពាហ៍ពោលគឺ ការលើកឡើងពីអនីតិសង្វាស ក្នុងគោលបំណងការពារផលប្រយោជន៍របស់អនីតិសង្វាសជននៅពេលដែលពួកគេបែកគ្នា។ ដោយឡែក ការអះអាងអំពីមោឃភាពក្នុងគោលបំណងបញ្ជាក់ថា គ្មានទំនាក់ទំនងនៃអាពាហ៍ពិពាហ៍រវាងគូភាគីដើម្បីអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតជាអាទិ៍។

ឧទាហរណ៍ទី៣៖ ភាគីនៃអាពាហ៍ពិពាហ៍ នារីឈ្មោះ "គ្រី នីតា" បុរសឈ្មោះ "លី សីហា" ដោយមានសាក្សី២រូបក្នុងពេលការ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ សាក្សីទី១ "លី សិហា" សាក្សីទី២ឈ្មោះ "នី ស្រីមុំ"។ មន្ត្រីអត្រានុកូលដ្ឋានបានចុះបញ្ជី សាក្សី "លី សិហា" ក្នុងក្រឡោនឈ្មោះភាគី (ភាគីនៃអាពាហ៍ពិពាហ៍ នារីឈ្មោះ "គ្រី នីតា" បុរសឈ្មោះ "លី សីហា") ប៉ុន្តែតាមពិត 'លី សិហា' មិនបានដាក់ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទេ។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍ រវាង "គ្រី នីតា" និង "លី សិហា" ត្រូវបានចាត់ទុកជាមោឃៈ ពីព្រោះ "លី សិហា" មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជាអាទិ៍។

ឧទាហរណ៍៤ ភាគីខាងនារី ឈ្មោះ គ្រី នីតា កើតថ្ងៃទី ១៤.០២.១៩៩៩ បុរសឈ្មោះ លី សីហា កើតថ្ងៃទី ២៤.០១.១៩៩៧ មន្ត្រីអត្រានុកូលដ្ឋានបានចុះថ្ងៃខែឆ្នាំកំណើតរបស់ភាគីខាងបុរសខុស ថ្ងៃទី ២៤.០១.១៩៩៥។

ការចុះឈ្មោះ ខុសអក្ខរាវិរុទ្ធ ឬ ខុសថ្ងៃខែឆ្នាំកំណើត ត្រូវបានចាត់ទុកថា ជាវិការៈបន្តិចបន្តួចក្នុងនីតិវិធី ហេតុនេះមិនធ្វើឲ្យអាពាហ៍ពិពាហ៍ត្រូវបានមោឃភាពនោះទេ ក្នុងករណីនេះអាពាហ៍ពិពាហ៍មានអានុភាព ។

**កថាភាគទី២៖ នីតិវិធីនៃការបញ្ជាក់មោឃភាព**

[32] មាត្រា៩៥៨ ចំណុច ខ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ជាទូទៅ កិច្ចសន្យាដែលមានមូលហេតុមោឃភាព កិច្ចសន្យានោះពុំមានអានុភាពតាំងពីដំបូងពោលគឺ អានុភាពនៃមោឃភាព ត្រូវកើតឡើងដោយស្វ័យប្រវត្តិ ដោយមិនត្រូវការសេចក្តីសម្រេចរបស់តុលាការនោះទេ។

អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍ ក៏មិនខុសពី អានុភាពនៃមោឃកិច្ចសន្យាធម្មតាដែរ ពោលគឺ មោឃភាពអាពាហ៍ពិពាហ៍កើតឡើងដោយស្វ័យប្រវត្តិនៅពេលដែលមានមូលហេតុមោឃភាព ។ ទោះបីជា អាពាហ៍ពិពាហ៍ ត្រូវបានមោឃៈ ប៉ុន្តែអានុភាពនេះ មិនបានធ្វើឲ្យបាត់បង់អានុភាពនៃការចុះបញ្ជីទេ ហេតុនេះ លុះត្រាតែធ្វើបណ្តឹងបញ្ជាក់អំពីមោឃភាព ទើបអាចលុបចោលនូវការចុះបញ្ជីអាពាហ៍ពិពាហ៍បាន។

ការទាមទារឲ្យបញ្ជាក់អំពីមោឃភាព ត្រូវធ្វើតាមផ្លូវតុលាការ ផ្អែកតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទង នឹងឋានៈបុគ្គល[33]។

មោឃភាពអាពាហ៍ពិពាហ៍ ទោះបីពុំមានការកើតឡើងនូវអាពាហ៍ពិពាហ៍តាមច្បាប់ក៏ដោយ មានករណី មួយចំនួននៃអាពាហ៍ពិពាហ៍ជាក់ស្តែងបានកើតឡើងហេតុនេះ ដើម្បីបញ្ជាក់ច្បាស់ថា គ្មានអាពាហ៍ពិពាហ៍ អ្នក មានផលប្រយោជន៍ពាក់ព័ន្ធ អាចធ្វើបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពបាន។

ក្នុងករណី ភាគីមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពុំបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជាអាទិ៍ អាពាហ៍ពិពាហ៍ ពុំត្រូវបានបង្កើតឡើងទេហើយជាមូលហេតុនៃមោឃភាព។ ក្នុងករណីនេះ អាពាហ៍ពិពាហ៍ពុំ មានអត្ថិភាពតាមទិដ្ឋភាពណាមួយ និងលក្ខណៈសារធាតុផង ហេតុនេះមិនអាចធ្វើបណ្តឹងទាមទារឲ្យបញ្ជាក់ អំពីមោឃភាពទេ។

### ១. អ្នកមានសិទ្ធិទាមទារឲ្យបញ្ជាក់អំពីមោឃភាព

ច្បាប់ពុំបានបញ្ញត្តអំពីអ្នកដែលមានសិទ្ធិធ្វើបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពទេ អាចបកស្រាយ ថាជនណាក៏អាចធ្វើបានដែរ ប៉ុន្តែ ដើម្បីធ្វើបណ្តឹងបញ្ជាក់ លុះត្រាតែ មានផលប្រយោជន៍នៃការធ្វើបណ្តឹង ហេតុ នេះជនដែលមានផលប្រយោជន៍នៃបណ្តឹងប៉ុណ្ណោះ ដែលអាចធ្វើបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាព[34]។ បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ក្នុងឧទាហរណ៍ខាងលើនេះ គឺ លី សិហា, លី សីហា, គ្រី នីតា, អាចធ្វើ បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពអាពាហ៍ពិពាហ៍ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។

នៅក្នុងករណី មាន A,C និង D ដោយ A និង D ជាឪពុកនិងកូន តែ A និង C មានចំណង អាពាហ៍ពិពាហ៍មួយដោយការភាន់ច្រឡំ។ ដូច្នេះ A និង C ជាបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ក្នុងការ បញ្ជាក់ មោឃភាពអាពាហ៍ពិពាហ៍ ដើម្បីអាចរៀបការថ្មី។ ក្រៅនេះ D ដែលជាឪពុករបស់ C ក៏អាចធ្វើបណ្តឹង

---

[33] មាត្រា៣ ចំណុច ក នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។

[34] មាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

បញ្ជាក់អំពីមោឃភាពដែរ ពីព្រោះបើអាពាហ៍ពិពាហ៍ត្រូវបានមោឃៈ AនិងD មិនមែនជាញាតិនឹងគ្នាទេ ហើយ D មិនចង់មាន ទំនាក់ទំនងញាតិជាមួយនឹងA ហេតុនេះ Dក៏ជាបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធក្នុងការធ្វើបណ្ដឹងដែរ។

**២. អាជ្ញាយុកាលនៃការប្ដឹងមោឃភាព**

នៅក្នុងទំនាក់ទំនងគតិយុត្តទូទៅ ករណីមាននូវមូលហេតុនៃការមោឃភាពអ្នកដែលមានសិទ្ធិត្រូវអនុវត្តសិទ្ធិក្នុងអំឡុងពេលនៃអាជ្ញាយុកាលកំណត់ ។ ប៉ុន្តែប្រសិនក្នុងករណីនៃការប្ដឹងមោឃភាពអាពាហ៍ពិពាហ៍ជាគោលការណ៍នៅក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៨៩ បានកំណត់អំពីអាជ្ញាយុកាលនៃមោឃភាព ។ "អាពាហ៍-ពិពាហ៍ត្រូវទុកជាមោឃភាព កាលបើសហព័ទ្ធណាម្នាក់ប្ដឹងថា ខ្លួនត្រូវគេចាប់បង្ខំអោយរៀបអាពាហ៍ពិពាហ៍[35]"។ ការប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្ដឹងនោះមិនធ្វើក្នុងរយៈពេល ៦ខែ គិតពីថ្ងៃដែលគេលែងបង្ខំនោះមក[36]។ ចំពោះករណីនៃការប្ដឹងមោឃភាពអាពាហ៍ពិពាហ៍ជាគោលការណ៍នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ពុំមានកម្រិតអំឡុងពេលអាជ្ញាយុកាលឡើយ។

**ផ្នែកទី២៖ ការលុបចោលអាពាហ៍ពិពាហ៍**

**កថាភាគទី១៖ មូលហេតុការលុបចោល**

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការប្រកាសទោទណ្ឌកម្មដែលលុបបំបាត់អានុភាពនៃអាពាហ៍-ពិពាហ៍ ឆ្ពោះទៅពេលអនាគតទៅតាមផ្លូវតុលាការ ដោយសារតែច្បាប់បានហាមឃាត់ អាពាហ៍ពិពាហ៍នោះទោះបីជាមាន ឆន្ទៈរៀបអាពាហ៍ពិពាហ៍នោះក៏ដោយ ។ អាពាហ៍ពិពាហ៍ដែលអាចលុបចោលបានមានន័យថា អាពាហ៍ពិពាហ៍ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍រួចហើយក៏ប៉ុន្តែការចុះសំបុត្រអាពាហ៍ពិពាហ៍នោះមានលក្ខ-ណៈមិនត្រឹមត្រូវតាមច្បាប់ដែលជាហេតុនាំឲ្យភាគីនីមួយៗ អាចលុបចោលអាពាហ៍ពិពាហ៍នោះបាន។ អាពាហ៍-ពិពាហ៍ដែលអាចលុបចោលបានគឺជាអាពាហ៍ពិពាហ៍មានលក្ខណៈ ផ្ទុយទៅនឹងបញ្ញត្តិច្បាប់ ដែលមានទាក់ទងនឹងផលប្រយោជន៍សាធារណៈ ពីមាត្រា៩៥២ រហូតដល់មាត្រា៩៥៨ និងផលប្រយោជន៍ឯកជន មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី ។ ការលុបចោលអាពាហ៍ពិពាហ៍គឺជាការរំលាយអាពាហ៍ពិពាហ៍ ដែលបានកើតមានឡើងហើយមានអានុភាពរួចហើយ ពោលគឺអាពាហ៍ពិពាហ៍នោះបានប្រព្រឹត្តឡើយដោយស្របតាមនីតិវិធី ក្នុងការរៀបអាពាហ៍ពិពាហ៍ គឺបានចុះបញ្ជីអាពាហ៍ពិពាហ៍ និងចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួចរាល់នឹង ស្របទៅតាមច្បាប់កំណត់។

---

[35] មាត្រា២៣ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

[36] មាត្រា២៣ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

**១. មិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍**

កាលពីឆ្នាំ ១៩៨៩ ព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថាបុរសអាយុចាប់ពី២០ឆ្នាំឡើងទៅ និង ចំណែកឯនារី គឺអាយុចាប់ពី១៨ឆ្នាំឡើងទៅទើបមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន[37]។ ចំពោះច្បាប់កម្ពុជាបច្ចុប្បន្នបានកំណត់ដោយ អាយុ១៨ឆ្នាំ ដែលជាអាយុដល់នីតិភាពមកជាអាយុអប្បបរមាដែលសមរម្យអាចរៀបអាពាហ៍ពិពាហ៍បាន។ ការកំណត់អំពីអាយុនៃបុគ្គលដែលរៀបអាពាហ៍ពិពាហ៍ គឺត្រូវបានកំណត់យ៉ាងច្បាស់ ដោយមិនអនុញ្ញាតឲ្យបុគ្គលណាអាចបំពានអំពីលក្ខខណ្ឌមួយនេះបានឡើយ គឺលើកលែងតែករណីពិសេសមួយចំនួនតែប៉ុណ្ណោះ។ ការកំណត់អំពីអាយុនៃភាគីអាពាហ៍ពិពាហ៍ គឺដើម្បីតម្រូវឲ្យបុគ្គលដែលរៀបអាពាហ៍ពិពាហ៍មានគ្រប់លក្ខណៈសម្បត្តិគ្រប់គ្រាន់នូវ ភាពទទួលខុសត្រូវចំពោះគ្រួសារ មានកាយសម្បទាពេញលេញមានបញ្ញាស្មារតី បរិបូរមានមុខរបរចិញ្ចឹមជីវិតច្បាស់លាស់ មានទំនួលខុសត្រូវគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនជាដើម បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។ យ៉ាងដូចនេះហើយ ទើបមានការហាមឃាត់ បុរស និងនារី ដែលមិនទាន់បានដល់នីតិភាព និងមិនទទួលបានអត្តាធីនភាពតាមច្បាប់ មិនអាចរៀបអាពាហ៍ពិពាហ៍បានទេ[38]។

**២. អាពាហ៍ពិពាហ៍ដែលដាច់សាច់ញាតិ**

**២.១. ញាតិលោហិត**

បុរស និងនារី ដែលជាភាគីនៃអាពាហ៍ពិពាហ៍ដែលបានដល់នីតិភាពហើយក្តី ក៏មិនអាចរៀបអាពាហ៍-ពិពាហ៍ជាមួយគ្នាបានដែរ ប្រសិនបើភាគីទាំងសងខាងជាញាតិលោហិត ខ្សែផ្ទាល់ ឬសាខា ញាតិលោហិត ក្នុង៣ថ្នាក់រាប់ទាំងថ្នាក់ទី៣ផង[39]។ ការរៀបអាពាហ៍ពិពាហ៍ ជាមួយថ្នាក់ជិតគ្នាបែបនេះ គឺត្រូវបានច្បាប់ហាមឃាត់ជាដាច់ខាត ចំពោះអាពាហ៍ពិពាហ៍រវាងគ្នានឹងគ្នា ដោយសារមូលហេតុនៃ សុជាតិវិទ្យា និងសីលធម៌សង្គម។ បើយោងទៅតាមមូលហេតុនៃសុជាតិវិទ្យា គឺការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នា នឹងបណ្តាលអោយកូនដែលកើតមកមានអាការៈខ្សោយ ប្រឈមមុខទៅនឹងជំងឺច្រើន ព្រមទាំងហានិភ័យនៃពិការភាព តាំងពីកំណើតខ្ពស់ជាងកុមារធម្មតា។ ដោយឡែកបញ្ហាសីលធម៌សង្គម ក៏ជាបញ្ហាដ៏ធំមួយផងដែរ ដោយវាផ្ទុយពីសីលធម៌សង្គមហើយសង្គមក៏មិនទទួលស្គាល់អាពាហ៍ពិពាហ៍បែបនេះដូចគ្នា។ជាការពិតណាស់ទោះបីជាមានការបញ្ជាក់នូវញាតិភាពរវាងឳពុកម្តាយចិញ្ចឹម ចំពោះកូនស្មុំពេញលេញ ឬកូនស្មុំធម្មតា ហើយក្តីក៏ច្បាប់បានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍នឹងគ្នាដែរ។ មួយវិញទៀតទោះបីមានការបញ្ជាក់ទំនាក់ទំនងញាតិរវាង កូនស្មុំនឹង ឪពុក

[37] មាត្រា៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

[38] មាត្រា៩៤៨ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[39] មាត្រា៩៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ម្ដាយបង្កើតបានកាត់ផ្ដាច់ដោយមូលហេតុនៃការបង្កើតកូនស៊ុំពេញលេញក៏ដោយក៏ទំនាក់ទំនងញាតិលោហិតតាមធម្មជាតិ មិនត្រូវបានកាត់ផ្ដាច់ដែរដូចនេះហើយការហាមឃាត់រវាងអាពាហ៍ពិពាហ៍ថ្នាក់ជិតនៅតែ ត្រូវបានហាមឃាត់ដដែល ចំពោះចំណងញាតិលោហិតខ្សែផ្ទាល់។

**២.២. ញាតិពន្ធ**

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយចំពោះញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុង៣ថ្នាក់រាប់ទាំងថ្នាក់ទី៣ផង[40] ។ ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់និងរវាងជនដែលធ្លាប់ជាញាតិពន្ធខ្សែផ្ទាល់[41]។ ដោយសារតែ ញាតិលោហិតនៃខ្សែផ្ទាល់របស់សហព័ទ្ធមានទំនាក់ទំនង ប្រហាក់ប្រហែលទៅនឹងញាតិលោហិតខ្សែផ្ទាល់របស់ខ្លួន ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្ដាយ និងកូនដូចនេះអាពាហ៍ពិពាហ៍បែបនេះក៏មិនមែនជាការគួរដែរ។ អាពាហ៍ពិពាហ៍ក៏មិនអាចធ្វើឡើងបានឡើយ រវាងញាតិពន្ធនៅក្នុង៣ថ្នាក់ ដោយរាប់ទាំងថ្នាក់ទី៣ផង ក៏ដោយក៏អាពាហ៍ពិពាហ៍នោះត្រូវបានហាមឃាត់ដែរ។ ពីព្រោះថានៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធទាំងនេះនិន្នាការបង្កើតទំនាក់ទំនងញាតិជារួម ដែលមានលក្ខណៈជិតស្និតស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិលោហិតដែរ។ ក៏ប៉ុន្តែដោយសារទំនៀមទម្លាប់របស់ប្រទេសកម្ពុជា មានករណីអាពាហ៍ពិពាហ៍រវាងបងប្អូនថ្លៃ ដូចជាករណីដែលសហព័ទ្ធម្ខាងទទួលមរណភាពទៅហើយសហព័ទ្ធម្ខាងទៀតបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយ បង ឬ ប្អូនថ្លៃរបស់សហព័ទ្ធជាដើម[42]។ ក្នុងគោលបំណងដើម្បីឲ្យជួយមើលថែរក្សា កូនរបស់បុគ្គលដែលទទួលមរណភាពនោះ។

**៣. ទ្វេពន្ធភាព**

បុរសដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ[43] ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព ប្រសិនបើបុរស ឬ នារីណាដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់បានរលាយនៅឡើយហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត[44]។ ដោយសារការអនុម័តយករបបឯកពន្ធភាព បុរសត្រូវបានហាមឃាត់មិនឲ្យ រៀបអាពាហ៍ពិពាហ៍ជាមួយនារីលើសពីមួយនាក់ ហើយចំណែកឯនារីក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយបុរសលើសពីមួយនាក់បានដូចគ្នា។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្ដីមួយ ប្រពន្ធមួយ[45] ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជា-

---

[40] មាត្រា៩៥២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[41] មាត្រា៩៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[42] មាត្រា៩៥២ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[43] មាត្រា ៤៥ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[44] មាត្រា៤ នៃច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ២០០៦។

[45] មាត្រា២ នៃច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ២០០៦។

ណាចក្រកម្ពុជា ហេតុនេះក្រមរដ្ឋប្បវេណីបានហាមឃាត់ចំពោះ បុគ្គលដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយគឺ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានទេ។

**៤. អាពាហ៍ពិពាហ៍អំឡុងពេលហាមឃាត់ ( ឬ ការមិនគោរពវិធវាភាព )**

ក្រោយពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងភាពជាមេម៉ាយ រយៈពេល៣០០ថ្ងៃ គិតចាប់ពីពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ដោយមូលហេតុប្តីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមដែលសម្រេចអំពី មោឃភាពនៃអាពាហ៍ពិពាហ៍ ឬពីថ្ងៃចេញសាលក្រមស្ថាពរនៃការលែងលះគ្នា ដោយយោងតាមមាត្រា ៩ ច្បាប់អាពាព៍ពិពាហ៍ និងគ្រួសារចាសឆ្នាំ១៩៨៩។ ក៏ប៉ុន្តែក្រមរដ្ឋប្បវេណីបច្ចុប្បន្ន បានកែប្រែអំពីអំឡុងពេលហាមឃាត់ គឺហាមឃាត់មិនឲ្យនារីរៀបអាពាហ៍ពិពាហ៍ថ្មីទៀតក្នុងអំឡុងពេល១២០ថ្ងៃ ថ្ងៃបន្ទាប់ពីការរលាយ ឬការលុបចោលអាពាហ៍ពិពាហ៍មុន ហេតុនេះស្ត្រីដែលបានលែងលះជាមួយស្វាមីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានលុះត្រារយៈពេល១២០ថ្ងៃបានកន្លងផុត[46]។ អាពាហ៍-ពិពាហ៍ទាំងឡាយណាដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ហើយបានរំលោភបំពាននូវចំណុចនេះគឺ នឹងត្រូវលុបចោល ។ អំឡុងពេលហាមឃាត់ស្ត្រីមិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី ជាអំឡុងពេលដែលច្បាប់កម្រិតសម្រាប់ស្ត្រី ដើម្បីជៀសវាងពីបញ្ហាជាមួយគ្នាក្នុងការកំណត់អំពីបិតុភាព។

**៥. អាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាម**

បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍មានវិការៈក្នុងការបង្ហាញឆន្ទៈដោយការឆបោក ឬការគំរាមកំហែងអាចទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន[47]។ ការឆបោក ឬការគំរាមគឺសំដៅលើការធ្វើឲ្យភាគីម្ខាង ទៀតយល់ព្រមរៀបអាពាហ៍ពិពាហ៍ ដោយសារមធ្យោបាយដ៏ខ្លាំងក្លាមួយដែលខុសច្បាប់ ដោយការបោកប្រាស់ឲ្យជននោះធ្លាក់ទៅក្នុងការភាន់ច្រឡំ ឬធ្វើឲ្យជននោះធ្វើតាមដោយការជូនដំណឹងអំពីភាពអាក្រក់ទៅភាគីម្ខាងទៀត។ ការឆបោក ឬការគំរាមចាំបាច់ត្រូវតែមានភាពផ្ទុយច្បាប់ដែលមានកម្រិតខ្ពស់ កើតឡើងដោយមធ្យោបាយដែលបានប្រើប្រាស់មានលក្ខណៈឆបោក ពាក់ព័ន្ធទៅ នឹងអសមត្ថភាពផ្លូវភេទ ឬចំណុចសំខាន់ផ្សេងទៀតជាសត្យានុម័ត ឬជាអត្តនោម័ត ឬដោយពាក្យសម្តី ឬអំពើគំរាមកំហែងជាដើម។ បញ្ញត្តិនេះគឺជាការកំណត់អំពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាផលប្រយោជន៍ឯកជនដើម្បីការពារអំពីផលប្រយោជន៍នៃភាគីអាពាហ៍ពិពាហ៍។

**កថាភាគទី២៖ អាជ្ញាយុកាលនៃការប្តឹងលុបចោល**

[46] មាត្រា៩៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[47] មាត្រា៩៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នៅក្នុងទំនាក់ទំនងគតិយុត្តទូទៅ ករណីមាននូវមូលហេតុនៃការលុបចោលនោះអ្នកដែលមានសិទ្ធិត្រូវអនុវត្តសិទ្ធិក្នុងអំឡុងពេលនៃអាជ្ញាយុកាលកំណត់ ។ ប៉ុន្តែប្រសិនក្នុងករណីនៃការប្ដឹងលុបចោលអាពាហ៍-ពិពាហ៍ជាគោលការណ៍មិនមានរយៈពេលកំណត់ទេ គឺអ្នកដែលមានសិទ្ធិក្នុងការប្ដឹងអាចដាក់ពាក្យបណ្ដឹងបាននៅពេលដែលខ្លួនបានដឹង អំពីការមិនស្របតាមច្បាប់នៃអាពាហ៍ពិពាហ៍របស់ខ្លួន ហើយភាគីមានបំណងចង់លុបចោលនូវអាពាហ៍ពិពាហ៍ដែលខុសច្បាប់នោះ។ ក៏ប៉ុន្តែលើកលែងតែការប្ដឹងលុបចោល អាពាហ៍ពិពាហ៍ដោយមូលហេតុអាយុ អំឡុងពេលហាមឃាត់ស្ត្រី និងការឆបោក ឬគំរាមប៉ុណ្ណោះ ទើបមានការកំណត់អំពីអំឡុងពេលច្បាស់លាស់ក្នុងការប្ដឹងទាមទារឲ្យលុបចោល។

**១. អាជ្ញាយុកាលកំណត់ដោយច្បាប់**

នៅពេលដែលជនមិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍សិទ្ធិ[48] ដែលអាចទាមទារឲ្យលុបចោលក៏ត្រូវបានរលត់ដោយមូលហេតុថា ការបំពានលើលក្ខខណ្ឌក្នុងការរៀបអាពាហ៍ពិពាហ៍ត្រូវបានជួសជុលរួចហើយ ដូច្នេះលែងប្រឆាំងទៅនឹងសង្គមទៀតហើយ ទោះបីជាជនក្រៅពីភាគីអនុវត្តសិទ្ធិលុបចោលក៏ដោយ ក៏ភាគីនៃអាពាហ៍ពិពាហ៍នោះ នៅតែអាចរៀបអាពាហ៍-ពិពាហ៍ម្ដងទៀតបានដដែល។ ជនដែលបានរៀបអាពាហ៍ពិពាហ៍ មិនអាចយកមូលហេតុអាយុដើម្បីប្ដឹង លុប-ចោលអាពាហ៍ពិពាហ៍ទេបើកាលណាអនីតិជននោះបានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ។ ទោះជាយ៉ាងនេះក្ដីជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិលុបចោលអាពាហ៍ពិពាហ៍ និងធ្វើ(សច្ចានុមតិ)[49] ក្នុងអំឡុងពេលបីខែ បន្ទាប់ពីជននោះបានដល់អាយុរៀបអាពាហ៍ពិពាហ៍[50]។ ការលុបចោលអាពាហ៍ពិពាហ៍ដោយមូលហេតុអាយុនេះវាមានជាផលប្រយោជន៍សម្រាប់ឯកជន ដូចនេះហើយ សិទ្ធិលុបចោលនឹងត្រូវរលត់បន្ទាប់ពីសាមីជនបានផ្ដល់សច្ចានុមតិក្នុងអំឡុងពេលបីខែនោះ។

**២. អាជ្ញាយុកាលដែលកើតឡើងដោយការបង្ហាញឆន្ទៈ**

**២.១. អាជ្ញាយុកាលស្ថិតក្នុងអំឡុងពេលហាមឃាត់**

អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងដោយផ្ទុយទៅនឹងបញ្ញត្តិនៃមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណីបច្ចុប្បន្នដែលមានបញ្ញត្តិស្ដីពីអំឡុង ពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត គឺពុំអាចទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍នោះបានឡើយ ប្រសិនរយៈពេល១២០ថ្ងៃបានកន្លងផុត។ ថ្វីត្បិតតែច្បាប់បានទុករយៈពេលសម្រាប់ការលុបចោលក៏ពិតមែន ប៉ុន្តែសិទ្ធិលុបចោលនោះនឹងត្រូវរលត់នៅរយៈពេល១២០ថ្ងៃ នៅពេលដែលរក

[48] មាត្រា៩៦១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[49] សច្ចានុមតិ មានន័យថា ការយល់ព្រមទទួលស្គាល់ដោយគ្មានអានុភាពប្រតិសកម្ម។

[50] មាត្រា៩៦១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឃើញថានារីនោះគ្មានផ្ទៃពោះ ។ សិទ្ធិលុបចោលនោះក៏ត្រូវបានរលត់ផលដែរក្នុងករណីនៅពេលដែលនារីនោះមានផ្ទៃពោះក្រោយការរៀបអាពាហ៍ពិពាហ៍ថ្មី។

**២.២. អាជ្ញាយុកាលដោយការឆបោក ឬគំរាម**

ការឆបោក ឬការគំរាមជា មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ដែលមានលក្ខណៈជាផលប្រយោជន៍ឯកជន ដូច្នេះសិទ្ធិលុបចោលនឹងត្រូវរលត់ នៅពេលដែលភាគីបានធ្វើសច្ចានុមតិ ឬបើអំឡុងពេលបីខែគិតចាប់ពីពេលដែលភាគីបានរកឃើញ អំពីការឆបោក ឬរួចផុតខ្លួនអំពីការគំរាមបានកន្លងផុតទៅ។

**កថាភាគទី៣៖ អ្នកមានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍**

ដោយសារតែករណីលុបចោលអាពាហ៍ពិពាហ៍មានលក្ខណៈខុសគ្នាពីមោឃភាពដែលមិនបាត់បង់អានុភាពដោយស្វ័យប្រវត្តិនោះទេ គឺត្រូវឲ្យមានអ្នកប្តឹងទាមទារទៅតាមផ្លូវតុលាការហេតុនេះហើយទើបច្បាប់កំណត់ឲ្យបុគ្គលមួយចំនួនដែល ជាអ្នកមានសិទ្ធិប្តឹងទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវទាំងនោះ។ អ្នកមានសិទ្ធិទាមទារឲ្យលុបចោលត្រូវបានប្រែប្រួលទៅតាមមូលហេតុនៃការលុបចោល ដូចនេះអ្នកដែលមានសិទ្ធិត្រូវធ្វើ ការលុបចោលតាមរយៈបណ្តឹងទាមទារឲ្យលុបចោល។

**១. ភាគីដែលរៀបអាពាហ៍ពិពាហ៍**

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍នៅពេល ដែលបានដឹងអំពីភាពមិនប្រក្រតីចំពោះអាពាហ៍ពិពាហ៍របស់ខ្លួនដែលមានលក្ខខណ្ឌចាំបាច់ក្នុងការហាមឃាត់ដូចជាមិនបាន គ្រប់អាយុក្នុងការរៀបអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍ជាមួយនឹងញាតិលោហិត ឬញាតិពន្ធ មិនឲ្យមានទ្វេពន្ធភាព អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី។

មានតែភាគីដែលរៀបអាពាហ៍ពិពាហ៍ដោយផ្ទាល់ទេ ទើបមានសិទ្ធិដាក់ពាក្យបណ្តឹងទាមទារឲ្យ លុបចោលនោះបាន ។ "បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាមអាចធ្វើការទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន[51]"។ ដើម្បីការពារជនដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬគំរាម សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ត្រូវបានផ្តល់ឲ្យតែចំពោះភាគីនៃអាពាហ៍ពិពាហ៍ តែប៉ុណ្ណោះដែលត្រូវបានប្រគល់ឲ្យ។ ភាគីម្ខាងនៃការលុបចោលគឺជាភាគីម្ខាងទៀតដោយតតិយជនផងដែរ។

**២. ញាតិសណ្តានរបស់ភាគី**

សាច់ញាតិរបស់ភាគីនីមួយៗ ក៏អាចដាក់ពាក្យបណ្តឹងឲ្យលុបចោលអាពាហ៍ពិពាហ៍បានដូចគ្នាប្រសិនបើដឹងថាអាពាហ៍ពិពាហ៍នោះបានផ្ទុយពីបញ្ញតិនៃ មាត្រា៩៦០ នៃក្រមរដ្ឋប្បវេណីបច្ចុប្បន្នដែលមានចែងអំពីការ

[51] មាត្រា៩៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

លុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់កំណត់ ។ ដោយគ្រាន់តែដាក់ពាក្យបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ទៅកាន់សាលាដំបូងរាជធានី ខេត្ត របស់ភាគីរស់នៅ។

### ៣. តំណាងអយ្យការ

មានតែនៅក្នុងបណ្ដឹងដែលទាក់ទងទៅនឹងឋានៈបុគ្គលទេ ដែលព្រះរាជអាជ្ញាមិនអាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងបាន។ ជាធម្មតាក្នុងនីតិវិធីនៃបណ្ដឹង ព្រះរាជអាជ្ញាគ្មានសិទ្ធិចូលរួមនោះទេ។ តំណាងអយ្យការអាចដាក់ពាក្យបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បាន [52] ប្រសិនបើយល់ឃើញថាចាំបាច់តែត្រូវការពារដល់ផលប្រយោជន៍សាធារណៈ [53] និងអំពីបុគ្គលដែលមានសិទ្ធិទាមទារឲ្យលុបចោល។ ម៉្យាងទៀតត្រូវកំណត់ផងដែរ អំពីការទាមទារត្រូវធ្វើឡើងដោយការដាក់ពាក្យបណ្ដឹងទៅតុលាការ ដោយសារតែអានុភាពនៃការលុប-ចោលអាពាហ៍ពិពាហ៍ ចាំបាច់ត្រូវធ្វើការកំណត់ជាស្ថាពរឲ្យមានលក្ខណៈជាឯកសណ្ឋាន។ ក្នុងករណីដែលភាគីគឺជាអនីតិជនជាដើម អ្នកដែលមានតួនាទីត្រូវការពារភាគីនោះ មិនមែនជាព្រះរាជអាជ្ញាទេតែគឺជា អ្នកតំណាងឲ្យផលប្រយោជន៍សាធារណៈ សិទ្ធិទាមទារឲ្យលុបចោលរបស់តំណាងអយ្យការនោះនឹងត្រូវរលត់ ប្រសិនបើសហព័ទ្ធម្ខាងទទួលមរណៈភាព។

### ៤. ទ្វេពន្ធភាព

ចំពោះករណីទ្វេពន្ធភាព ឬការបំពានអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីវិញសហព័ទ្ធរបស់ភាគី ឬ សហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន ក៏អាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បានដែរ[54]។ នៅពេលដែលអាពាហ៍ពិពាហ៍ចាស់មិនទាន់បានរលត់ជាស្ថាពរនៅឡើយហើយភាគីម្ខាងបានលួចលាក់ទៅរៀបអាពាហ៍-ពិពាហ៍ថ្មីមួយទៀតសហព័ទ្ធម្ខាងដែលជាភាគីនៃអាពាហ៍ពិពាហ៍ចាស់ក៏មានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ថ្មីនោះ បានដោយមូលហេតុអាពាហ៍ពិពាហ៍ចាស់មិនទាន់បានរលត់ជាស្ថាពរ តាមរយៈសាលក្រមរបស់តុលាការ។

## កថាភាគទី៤៖ នីតិវិធីនៃការលុបចោលអាពាហ៍ពិពាហ៍

ភាគីដែលមានបំណងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល [55]។ បណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មានគោលបំណងបង្កើត ឬ បញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គល ពោលគឺសំដៅទៅលើបណ្ដឹងដែលបង្កើត អានុភាពនូវការបង្កើត អានុភាពកំណត់ជាស្ថាពរនូវ

---

[52] មាត្រា៩៦០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[53] មាត្រា៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[54] មាត្រា៩៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[55] មាត្រា៣ ចំណុច ខ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។

អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គលបច្ចុប្បន្នកាល ឬអតីតកាលតាមរយៈសាលក្រម ឬ សាលដីកាស្ថាពរដែលទទួលស្គាល់នូវការ ទាមទារក្នុបណ្តឹងនោះដូចជា បណ្តឹងបញ្ជាក់អំពី អត្ថិភាព ឬនត្ថិភាព នៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ឬនត្ថិភាពនៃទំនាក់ទំនងបិតុភាព(មាតុភាព) ជាដើម។

**១. សមត្ថកិច្ចតុលាការ**

ការកំណត់ជាស្ថាពរនូវទំនាក់ទំនងប្តីប្រពន្ធ តាមបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍មានលក្ខណៈ ជាផលប្រយោជន៍សាធារណៈ ហេតុនេះចាំបាច់ត្រូវសម្របទៅនឹងតម្រូវការ ក្នុងការស្វែងរកការពិតជាក់ស្តែងព្រមទាំងតម្រូវការក្នុងការរកដំណោះស្រាយវិវាទទាំងស្រុង តាមរយៈការវិនិច្ឆ័យតែមួយលើក។ ដូច្នេះហើយចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់នូវតុលាការដែលចាត់ការបណ្តឹងទាមទារឲ្យ លុបចោលអាពាហ៍-ពិពាហ៍នេះ ហើយធ្វើការកំណត់នូវដែនសមត្ថកិច្ចរបស់តុលាការឲ្យបានច្បាប់លាស់ ដោយកំណត់យកទីកន្លែងដែលអាចមានសាមីភាគី ញាតិ ឬមិត្តភក្តិ ជាអាទិ៍ ដែលជាភស្តុតាងល្អៗ ដើម្បីសម្រួលនូវការធ្វើការអះអាងនិងបញ្ជាក់របស់ភាគី និងសម្រួលនូវការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺជាការសមរម្យ។ ជាលទ្ធផលច្បាប់បានកំណត់យក សមត្ថកិច្ចតុលាការផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីដែលពាក់ព័ន្ធនឹងបណ្តឹងនេះ[56] ក្នុងការដោះស្រាយវិវាទ ។ ប៉ុន្តែបើលំនៅឋានរបស់ភាគីពុំស្ថិតនៅក្នុងព្រះ-រាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេសមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមទីសំណាក់។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះត្រូវកំណត់តាមលំឋានចុងក្រោយ[57]។ ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ចបាន បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ[58]។ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវនៃនីតិវិធី ឬដើម្បីឲ្យមានសមធម៌រវាងគូភាគីតុលាការអាចផ្ទេរបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចតាមពាក្យសុំឬដោយឆន្ទានុសិទ្ធិបានដោយពិចារណាអំពីលំនៅឋានរបស់ភាគី និង សាក្សីដែលត្រូវសាកសួរ និង កាលៈទេសផ្សេងៗទោះបីបណ្តឹងនោះស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ[59]។

**២. បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍**

បណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមប្រកាស

---

[56] មាត្រា៥ ចំណុច ក នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។

[57] មាត្រា៥ ចំណុច ខ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។

[58] មាត្រា៥ ចំណុច គ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។

[59] មាត្រា៦ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។

រំលត់នូវចំណងអាពាហ៍ពិពាហ៍ ដោយផ្អែកលើមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះ ។ ជាគោលការណ៍សកម្មភាពនៃបណ្តឹងនេះ ត្រូវធ្វើឡើងតាមវិធីដាក់ពាក្យបណ្តឹង។

### ២.១. របៀបដាក់ពាក្យបណ្តឹង

ពេលដែលភាគី ឬ តតិយជនបានដឹងថាអាពាហ៍ពិពាហ៍បានកើតឡើងដោយ បំពានល័ក្ខខ័ណ្ឌណាមួយបុគ្គលនោះអាចដាក់ពាក្យបណ្តឹងទៅតុលាការបានពោលគឺនីតិវិធីបណ្តឹងត្រូវចាប់ផ្តើមពីពេលដែលមានការដាក់ពាក្យបណ្តឹងកើតឡើង ។ "ការដាក់បណ្តឹងត្រូវធ្វើឡើងដោយពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរទៅតុលាការ[60]"។ មានន័យថាការប្តឹង គឺជាសកម្មភាពមួយដែលទាមទារឲ្យមានការបំពេញនូវលក្ខខណ្ឌជាក់លាក់មួយជាកំណត់នោះគឺការប្រគល់នូវពាក្យបណ្តឹង ដើម្បីបង្គាប់ឲ្យបានច្បាស់លាស់នូវអង្គហេតុនៃការធ្វើបណ្តឹងតាមនីតិវិធី។

### ២.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

ចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់៖

ចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់នៃពាក្យបណ្តឹងជា ចំណុចដែលត្រូវសរសេរដើម្បីឲ្យពាក្យបណ្តឹងមានសុពលភាព។ ពេលខ្វះចំណុចនេះពាក្យបណ្តឹងនឹងគ្មានសុពលភាពនោះ តុលាការត្រូវបង្គាប់ឲ្យកែតម្រូវនូវកង្វះខាតនេះប្រសិនបើមិនបានធ្វើការកែតម្រូវទេតុលាការ ត្រូវលើកបណ្តឹងនោះចោល[61]។

ចំណុចដែលត្រូវសរសេរក្រៅពីនេះរួមមាន៖

"ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ព្រមទាំង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់កំណត់។ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ។ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ[62]"។

ចំណុចដែលត្រូវសរសេរក្រៅពីនេះ ៖

ចំណុចដែលត្រូវសរសេរក្រៅពីចំណុចចាំបាច់ដែលត្រូវសរសេរបញ្ជាក់ជាចំណុចដែលត្រូវសរសេរដោយស្ម័គ្រចិត្ត។ វាមិនមែនជាចំណុចសុពលភាពនៃបណ្តឹងទេ ប៉ុន្តែដើមចោទគប្បីសរសេរចំណុចនេះដើម្បីជា មូលដ្ឋាននៃការឆ្លើយតបរបស់ចុងឆ្លើយ និងជៀសវាងការយឺតយ៉ាវ។

ចំណុចត្រូវសរសេររួមមាន៖

---

[60] មាត្រា៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[61] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[62] មាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ (អង្គហេតុចម្បង)[63]។ អង្គហេតុសំខាន់ៗដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ ភស្តុតាង មធ្យោបាយតទល់ ឬ ការពារខ្លួន។ ការបរិច្ឆេទហត្ថលេខា។ គួរបញ្ជាក់ផងដែរថាពាក្យបណ្ដឹងមិនអាចលើកចោលដោយហេតុខ្វះនូវចំណុចទាំងនេះទេ។

### ៣. ការបង់ពន្ធប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដី គឺជាប្រាក់ពន្ធ ឬសោហ៊ុយដែលភាគីត្រូវបង់សម្រាប់ចាត់ការរឿងក្ដីរបស់ខ្លួនទៅតុលាការតាមបញ្ញត្តិច្បាប់។ ប្រាក់ប្រដាប់ក្ដីត្រូវគណនា ដោយផ្អែកលើមូលដ្ឋានៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្ដឹងនោះ។ ការទាមទារច្រើនចំណុចក្នុងបណ្ដឹងតែមួយ តម្លៃសរុបនៃការទាមទារទាំងនោះ ត្រូវបានចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្ដឹង[64] ។ ក្នុងករណីដែលមានការពិបាកក្នុងការគណនាតម្លៃដែលបានកំណត់ខាងលើតុលា-ការត្រូវកំណត់តម្លៃនោះដោយឆន្ទានុសិទ្ធិសមហេតុផល ។ បើតម្លៃនោះមិនអាចគណនាបានទេ នោះត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០(ប្រាំលានប្រាំសែន)រៀល[65]។

### ៣.១. ប្រភេទប្រាក់ប្រដាប់ក្ដី

ពន្ធដាក់ពាក្យសុំ៖ គឺជាប្រាក់ពន្ធដែលភាគីត្រូវបង់ក្នុងការដាក់ពាក្យបណ្ដឹង ឬពាក្យសុំសម្រាប់ចាត់ការរឿងក្ដីរបស់ខ្លួនទៅតុលាការតាមបញ្ញត្តិច្បាប់រួមមាន ពន្ធដាក់ពាក្យបណ្ដឹង និងពន្ធដាក់ពាក្យសុំ។ ចំនួនទឹកប្រាក់ដែលត្រូវគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង[66]។ ការបង់ពន្ធត្រូវធ្វើ ដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ។ ពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកជាពាក្យសុំមិនស្របច្បាប់[67]។ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ៖ គឺជាប្រាក់ប្រដាប់ក្ដីតុលាការដែលភាគី ឬបុគ្គលដែលទាក់ទង និងរឿងក្ដីត្រូវបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការដែល ធ្វើសកម្មភាពតាមនីតិវិធីនៅក្នុង បណ្ដឹងរដ្ឋប្បវេណី។ សកម្មភាពតាមនីតិវិធី នៅក្នុងបណ្ដឹងរដ្ឋប្បវេណីមានដូចជា៖ ការពិនិត្យ ភស្តុតាង ការបញ្ជូន ឯកសារ ឬសកម្មភាពផ្សេងៗតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី សោហ៊ុយ សម្រាប់ធ្វើដំណើរ ស្នាក់នៅរបស់ ចៅក្រម ក្រឡាបញ្ជី ក្នុងការពិនិត្យភស្តុតាង ស្រាវជ្រាវអង្គហេតុ សាកសួរសាក្សី ដែលប្រព្រឹត្តនៅក្រៅតុលាការ[68] ។

ប្រាក់ប្រដាក់ក្ដីភាគី៖ ជាប្រភេទមួយនៃប្រាក់ប្រដាក់ក្ដីដែលកំណត់ដោយតុលាការដែលគិតពិចារណានូវលក្ខណៈនៃរឿងក្ដី ឬ លទ្ធផលទ្រព្យធនរបស់ ភាគីជាអាទិ៍ សម្រាប់ថ្លៃធ្វើលិខិតបណ្ដឹង លិខិតពាក្យសុំ សោហ៊ុយ

---

[63] មាត្រា៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[64] មាត្រា៦០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[65] មាត្រា៦០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[66] មាត្រា៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[67] មាត្រា៦១ កថាខណ្ឌទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[68] មាត្រា៦២ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ធ្វើដំណើរ ឬសោហ៊ុយផ្សេងៗ[69]។

### ៣.២. បន្ទុកនៃប្រាក់ប្រដាប់ក្តី

បន្ទុកនៃប្រាក់ប្រដាប់ក្តីត្រូវធ្លាក់ទៅលើ៖

ភាគីចាញ់ក្តី ប៉ុន្តែបើចាញ់មួយភាគ តុលាការត្រូវសម្រេចដោយឆន្ទានុសិទ្ធិ។ ភាគីឈ្នះក្តី បើភាគីនោះប្រព្រឹត្តសកម្មភាពមិនចាំបាច់ ឬ ធ្វើឲ្យនីតិវិធីយឺតយ៉ាវ។ សហាបណ្តឹង ត្រូវទទួលបន្ទុកស្មើគ្នា ឬ ដោយសាមគ្គី ប៉ុន្តែអាចឲ្យភាគីសហាបណ្តឹងទទួលបន្ទុកច្រើនជាង សហាបណ្តឹងផ្សេងទៀតបាន ករណីដែលភាគីសហាបណ្តឹងនោះប្រព្រឹត្តសកម្មភាពដែលមិនចាំបាច់។ អ្នកតំណាងដែលច្បាប់កំណត់ អ្នកតំណាងដោយអាណត្តិ ឬក្រឡាបញ្ជីបានធ្វើឲ្យចំនួនទឹកប្រាក់ប្រដាប់ក្តីដែលគ្មានប្រយោជន៍កើតឡើងដោយចេតនា ឬដោយមានកំហុសធ្ងន់ធ្ងររបស់ខ្លួន ត្រូវសងប្រាក់ប្រដាប់ក្តីនោះវិញ ដោយដីកាសម្រេចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ[70]។ ក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានតំណាងអយ្យការជាភាគី ប្រាក់ប្រដាប់ក្តីដែលតំណាងអយ្យការត្រូវទទួលបន្ទុកជាបន្ទុករបស់រដ្ឋ[71]។ តំណាងអយ្យការ ក៏ជាអ្នកចូលរួមជាភាគីក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែរដើម្បីសម្រេចនូវផលប្រយោជន៍សាធារណៈក្នុងការបង្កើត ឬ ការបញ្ជាក់នូវទំនាក់ទំនងឋានៈបុគ្គលក្នុងករណីដែលគ្មានភាគីនៃទំនាក់ទំនងឋានៈបុគ្គលដូច្នេះទោះជាតំណាងអយ្យការបានចាញ់ក្តីក៏ដោយ ក៏មិនគួរឲ្យតំណាងអយ្យការនោះទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីដោយផ្ទាល់ខ្លួនដែរ។

## ៤. ការចាត់ចែងពាក្យបណ្តឹង

ពេលមានវិវាទ ឬ ហេតុដែលឈានដល់ការប្តឹងលុបចោលអាពាហ៍ពិពាហ៍កើតឡើង ភាគីដើមចោទនឹងធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ក្នុងបំណងទាមទារកម្មវត្ថុពីចុងចម្លើយ ដែលទាក់ទងនឹងវិវាទនោះ។ ការណ៍នៃការទទួលពាក្យបណ្តឹង ការពិនិត្យពាក្យបណ្តឹង ការបញ្ជូនពាក្យបណ្តឹង និងការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់មិនមានបញ្ញត្តិពិសេសសម្រាប់អនុវត្តក្នុងនីតិវិធីបណ្តឹទាក់-ទងឋានៈបុគ្គលទេ ហេតុនេះការអនុវត្តត្រូវយកតាមវិធានដែលមានបញ្ញត្តិក្នុងនីតិវិធីបណ្តឹងធម្មតា ពោលគឺ ក្រមនីតិវិធីរដ្ឋប្បវេណី។

### ៤.១. ការទទួលពាក្យបណ្តឹង

ពាក្យបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ជាលាយល័ក្ខណ៍អក្សរ ដែលដាក់ដោយដើមចោទទៅតុលាការ ត្រូវបានក្រឡាបញ្ជីដែលទទួលពាក្យបណ្តឹងនោះ បោះត្រាដែលបានចុះថ្ងៃ ខែ ឆ្នាំទទួលពាក្យបណ្តឹង

[69] មាត្រា៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[70] មាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[71] មាត្រា១០ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។

ដើម្បីបញ្ជាក់ពីពេលវេលានៃការដាក់ពាក្យបណ្តឹងនោះឲ្យបានច្បាស់ហើយ ធ្វើសំណុំរឿងនៃបណ្តឹងនោះដោយបន្ថែមក្រប ព្រមទាំងចុះលេខបណ្តឹង ។ បន្ទាប់មកក្រឡាបញ្ជីត្រូវតែបែងចែកសំណុំរឿងនៃបណ្តឹងនោះទៅឲ្យចៅក្រមដែលទទួលបន្ទុករឿងក្តីនោះ តាមលំដាប់នៃការបែងចែករឿងក្តីដែលកំណត់ប្រចាំឆ្នាំ ដោយប្រធានតុលា-ការ។ ករណីចៅក្រមទទួលបន្ទុកមានធុរៈ មិនអាចចាត់ការបណ្តឹងនោះបានទេ ត្រូវបែងចែកទៅឲ្យចៅក្រមផ្សេងទៀតទៅតាមលំដាប់សម្រាប់ជំនួស ដែលត្រូវបានកំណត់ជាមុនដោយប្រធានតុលាការ[72]។ កាបែងចែករឿងក្តីនៅតុលាការមួយនិង លំដាប់សម្រាប់ជំនួសមិនអាចត្រូវប្តូរក្នុងឆ្នាំនោះបានឡើយ លុះត្រាតែមាន មូលហេតុដែលពុំអាចជៀសវាងបាន។ មូលហេតុនោះរួមមាន៖ ចៅក្រមណាម្នាក់មានការងារច្រើនពេក ឬ ករណីចៅក្រមត្រូវឈប់ ឬ ប្តូរទៅតុលាការផ្សេង ឬ ករណីដែលចៅក្រមបន្តមានធុរៈដោយសារហេតុផលដូចជាត្រូវឈប់សម្រាកក្នុងរយៈពេលវែងជាអាទិ៍។ ការផ្លាស់ប្តូរចំពោះករណីនេះត្រូវកំណត់ដោយដីកា សម្រេចរបស់ប្រធានតុលាការ។

### ៤.២. ការពិនិត្យពាក្យបណ្តឹង

ក្រោយទទួលបានពាក្យបណ្តឹង ចៅក្រមទទួលបន្ទុកដែលបានទទួលការចាត់តាំង ត្រូវធ្វើការពិនិត្យអំពីភាពសមស្រប ឬ មិនសមស្របនៃពាក្យបណ្តឹង ដោយពិនិត្យលើលក្ខខណ្ឌទម្រង់(ចំណុចដែល ត្រូវសរសេរក្នុងពាក្យបណ្តឹង) និងពន្ធដាក់ពាក្យបណ្តឹង។ បើពិនិត្យឃើញថា មានការខ្វះខាតចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ឬ មិនបានបង់ពន្ធដាក់ពាក្យសុំ ចៅក្រមត្រូវចេញដីកាបង្គាប់ឲ្យកែតម្រូវ ដោយមានកំណត់អំឡុងពេលសមរម្យមួយ។ ប្រសិនបើដើមចោទមិនបានធ្វើការកែតម្រូវក្នុងអំឡុងពេលដែលបានកំណត់ទេ តុលាការត្រូវលើកចោលពាក្យបណ្តឹងដោយដីកាសម្រេច[73] ។ បើមានការមិនពេញចិត្តនឹងដីកាសម្រេចនេះដើមចោទអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍បាន ។ តុលាការអាចបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ សម្រាប់កោះហៅភាគីដោយកំណត់អំឡុងពេលសមរម្យ ។ បើមិនបានបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធនេះទេ តុលាការអាចចេញដីការសម្រេចលើបណ្តឹងនោះចោលដោយគ្មានការតវ៉ាពីចុងចម្លើយ តែដីកានេះអាចប្តឹងជំទាស់បាន[74]។

### ៤.៣. ការបញ្ជូនពាក្យបណ្តឹង

ក្រោយការពិនិត្យពាក្យបណ្តឹង បើតុលាការទទួលស្គាល់ថាពាក្យបណ្តឹងនោះត្រឹមត្រូវតាមទម្រង់ ហើយក្រឡាបញ្ជីត្រូវទទួលបន្ទុកការបញ្ជូនពាក្យបណ្តឹងនោះ[75] ទៅឲ្យចុងចម្លើយ។ ការបញ្ជូនមានច្រើនប្រភេទដូចជា៖

ការបញ្ជូនដោយប្រគល់ ៖ ការបញ្ជូនដោយប្រគល់ត្រូវធ្វើឡើងដោយវិធីប្រគល់នូវឯកសារទៅឲ្យជន

[72] មាត្រា២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[73] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[74] មាត្រា៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[75] មាត្រា២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ដែលត្រូវទទួលការបញ្ជូននោះ[76]។ ករណីអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុក កិច្ចការបញ្ជូន គប្បីពន្យល់នូវខ្លឹមសារនៃឯកសារនៅពេលប្រគល់។

ការបញ្ជូនដោយការជួបប្រទះ ៖ បើជនដែលត្រូវទទួលការបញ្ជូន ពុំច្បាស់ថាមានលំនៅឋាន ឬទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលជួបជននោះលើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែល ត្រូវធ្វើការបញ្ជូន នោះមន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវបញ្ជូនទៅកាន់ទីកន្លែងដែលបានជូនដំណឹងនោះ[77] ។ ម៉្យាងទៀតទោះបីមានលំនៅឋានទី-សំណាក់ ទីកន្លែងអាជីវកម្ម ឬមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវទទួលការបញ្ជូនក៏ដោយ មន្ត្រីទទួលបន្ទុកការបញ្ជូនក៏អាចបញ្ជូននៅទីកន្លែងដែលបានជួបប្រទះបានដែរ បើជននោះមិនប្រកែកចំពោះការទទួលការបញ្ជូននោះទេ។

ការបញ្ជូនដោយបង្គ្រប់កិច្ច ៖ ក្នុងករណីមិនជួបជនដែលត្រូវបានទទួលការបញ្ជូននៅទីកន្លែងដែលត្រូវទទួលការបញ្ជូនទេ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន អាចប្រគល់ឯកសារនោះទៅអ្នកបម្រើ ឬ បុគ្គលផ្សេងទៀតធ្វើការនៅទីនោះ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ[78]។ បុគ្គលដែលចាត់ទុកថាមានការយល់ដឹងសមរម្យត្រង់ចំណុចនេះសំដៅលើ អ្នកដែលយល់អំពីអត្ថន័យនៃការបញ្ជូន សារៈសំខាន់នៃការបញ្ជូននិងមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឲ្យជនដែលត្រូវទទួលការបញ្ជូន។

ការបញ្ជូនដោយទុកចោល ៖ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ ជនដែលត្រូវទទួលការបញ្ជូនដោយបង្គ្រប់កិច្ចតាមមាត្រា ២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវទេ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន អាចទុកឯកសារដែលជាកម្មវត្ថុនៃការបញ្ជូននោះចោលនៅទីកន្លែងនោះបាន ដែលការអនុវត្តបែបនេះមានអានុភាពជាការបញ្ជូន និងត្រូវបានទទួលស្គាល់ដោយច្បាប់ជាធរមាន។

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ៖ ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានគឺ ត្រូវគោរពនូវលក្ខខណ្ឌណាមួយក្នុងចំណោទលក្ខខណ្ឌទាំងអស់ ក្រឡាបញ្ជីអាចធ្វើការផ្សាយជាសាធារណៈ និងបន្ទាប់ពីមានការអនុញ្ញាតពីតុលាការ។ ជាគោលការណ៍ ដើម្បីអាចធ្វើការបញ្ជូនជាសាធារណៈបាន គឺត្រូវមានពាក្យសុំពីភាគីដែលសុំឲ្យតុលាការធ្វើការបញ្ជូនតាមរយៈ ការផ្សាយជាសាធារណៈ និងបន្ទាប់ពីមានការអនុញ្ញាតពីតុលាការ។ តែដើម្បីជៀសវាងការយឺតយ៉ាវតុលាការក៏អាច បង្គាប់ឲ្យក្រឡាបញ្ជី ធ្វើការបញ្ជូនតាមការផ្សាយជា

[76] មាត្រា២៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[77] មាត្រា២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[78] មាត្រា២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

សាធារណៈដោយឆន្ទានុសិទ្ធិបានទោះបីគ្មានពាក្យសុំពីភាគីក៏ដោយ[79]។

ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ត្រូវទាមទារឲ្យដើមចោទត្រៀមនូវឯកសារចម្លងនៃពាក្យបណ្តឹងទៅតាមចំនួនដែលត្រូវការតាមចំនួននៃចុងចម្លើយហើយបញ្ជូនឯកសារសរសេរចម្លងនៃពាក្យបណ្តឹងនោះទៅឲ្យចុងចម្លើយចំណែក ឯកសារដើមនៃពាក្យបណ្តឹងត្រូវរក្សាទុកដោយតុលាការ។

ករណីមិនអាចបញ្ជូនបានដោយហេតុ អាសយដ្ឋានរបស់ចុងចម្លើយដែលសរសេរក្នុងពាក្យបណ្តឹងនោះមិនត្រឹមត្រូវ ឬ មិនបានបង់សោហ៊ុយចាំបាច់ជាមុនសម្រាប់ធ្វើការបញ្ជូន តុលាការត្រូវបង្គាប់ឲ្យធ្វើការកែតម្រូវដោយកំណត់អំឡុងពេលដើម្បីកែតម្រូវ ដូចក្នុងករណីដែលមានកង្វះក្នុងការសរសេរក្នុងពាក្យបណ្តឹងដែរ។

ទោះបីជាដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការក៏ដោយ ទំនាក់ទំនងគតិយុត្តនឹងកើតមានឡើងរវាងតុលាការ និង ដើមចោទប៉ុណ្ណោះ រហូតដល់ពេលដែលពាក្យបណ្តឹងនោះត្រូវបានបញ្ជូនទៅចុងចម្លើយ។ តាមរយៈការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ ចុងចម្លើយនឹងក្លាយជាប្រធាននៃនីតិវិធីនៃបណ្តឹងនោះ ហើយទំនាក់ទំនងគតិយុត្ត រវាងភាគីទាំងបី គឺតុលាការ ដើមចោទ និង ចុងចម្លើយ នឹងកើតមានឡើងពីពេលនោះ។ ក្នុងន័យនេះការដាក់ពាក្យបណ្តឹង ត្រូវបានសម្រេចដោយការបញ្ជូនពាក្យបណ្តឹងនោះទៅឲ្យចុងចម្លើយ។

### ៤.៤. ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់

ពេលដែលបណ្តឹងបានដាក់ តុលាការត្រូវធ្វើការកំណត់យ៉ាងឆាប់រហ័សនូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាកាលបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់អំឡុងពេល ៣០ថ្ងៃ គិតពីពេល ដែលពាក្យបណ្តឹងត្រូវបានដាក់និងកោះហៅគូភាគីចូលសវនាការតាមកាលបរិច្ឆេទនេះ[80]។ ក្នុងទិដ្ឋភាពនៃការ អនុវត្តជាក់ស្តែងក្រោយពីបានពិនិត្យ ហើយបានទទួលពាក្យបណ្តឹង តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធី នៃការទាញហេតុផលលើកដំបូង ហើយត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងព្រមជាមួយនឹងដីកាកោះហៅចុងចម្លើយ ឲ្យមកតុលាការតាមកាលបរិច្ឆេទកំណត់នេះ ។ តុលាការនឹងមិនអាចធ្វើការបញ្ជូនពាក្យបណ្តឹង ព្រមគ្នានឹងដីកាកោះហៅចុងចម្លើយស្តីពីកាលបរិច្ឆេទលើកដំបូងបានទេ ប្រសិនបើពុំបានបង់សោហ៊ុយជាមុន ហើយពាក្យបណ្តឹងនោះនឹងត្រូវលើកចោលដោយតុលាការ[81]។

### ៥. នីតិវិធីនៃការត្រៀម និងទាញហេតុផលផ្ទាល់មាត់

ក្រោយពីបានបញ្ជូនពាក្យបណ្តឹង ដោយមានការចូលរួមរបស់ភាគី តុលាការនឹងធ្វើការសម្រេចសេចក្តីអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ និង ចេញសាលក្រម។ ការសម្រេច

---

[79] មាត្រា២៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[80] មាត្រា៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[81] មាត្រា៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

សេចក្ដីលើបណ្ដឹងនេះ ត្រូវធ្វើឡើងតាមវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។

មុននឹងឈានដល់ការវិនិច្ឆ័យ តាមរយៈនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ តុលាការត្រូវអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន ដើម្បីធានាឲ្យបាននូវការទាញហេតុផលដោយផ្ទាល់មាត់មួយដែលល្អិតល្អន់ និងទទួលបាននូវសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិតជាក់ស្ដែង។

### ៥.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលរៀបចំដើម្បីលើកកម្ពស់ និងសម្រួលដល់ការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងគោលបំណងធ្វើការបំភ្លឺអំពីចំណុចវិវាទ រវាងភាគីដោយរៀបចំជាមុននូវសេចក្ដីអះអាងរបស់ភាគី និង ធ្វើការរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវធ្វើការ ពិនិត្យ។ នៅក្នុងការទាញហេតុផលផ្ទាល់មាត់ ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុផ្សេងៗ ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់ខ្លួនឯង ដោយមិនបានគិតថាអង្គហេតុនោះមាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្ដីនោះទេ។ ស្របគ្នាដែរភាគីម្ខាងៗ តែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុរបស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង។ ជាលទ្ធផល ការធ្វើបែបនេះនឹងនាំ ឲ្យការជម្រះក្ដីមានភាពស្មុគស្មាញ ព្រមទាំងអូសបន្លាយដោយឥតប្រយោជន៍ និង ធ្វើឲ្យលំបាកក្នុងការស្វែងរកការពិត។ ដូច្នេះហើយបានជា ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថានៅមុនការជម្រះក្ដីដោយការទាញហេតុផលដោយផ្ទាល់មាត់គ្មានភាពស្មុគស្មាញ គ្មានអូសបន្លាយពេលវេលាដោយឥតប្រយោជន៍ និង ងាយស្រួលក្នុងការស្វែង រកការពិតដើម្បីឆ្លើយតបនឹងការទទួលខុសត្រូវរបស់តុលាការ ដែលច្បាប់បានបញ្ញត្តិដោយតម្រូវឲ្យតុលាការ ត្រូវប្រឹងប្រែងដើម្បីរ៉ាប់រងបណ្ដឹងរដ្ឋប្បវេណីឲ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស[82]។

អវត្តមានចុងចម្លើយក្នុងនីតិវិធីត្រៀមទាញហេតុផលនេះ មិនអាចចាត់ទុកថាការសារភាពទេ ពោលគឺតុលាការទុកសិទ្ធិឲ្យចុងចម្លើយក្នុងការចូលរួម ឬ មិនចូលរួមក្នុងនីតិវិធីត្រៀមទាញហេតុផលនេះ ហើយគ្រប់ការអះអាងអង្គហេតុរបស់ភាគី ទោះបីជាការសារភាព ឬ មិនសារភាពក៏តុលាការធ្វើការទទួលស្គាល់អង្គហេតុឲ្យស្របទៅនឹងការពិតជាក់ស្ដែង ដោយពឹងផ្អែកលើគោលការណ៍ជំនឿទុកចិត្តដោយសេរីរបស់ខ្លួន។

### ៥.២. នីតិវិធីទាញហេតុផលផ្ទាល់មាត់

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទ នៃការទាញហេតុផលផ្ទាល់មាត់[83]។ ក្រៅពី

---

[82] មាត្រា៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[83] មាត្រា១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ការបញ្ជាក់អំពីអង្គហេតុ និងភស្តុតាងដែលនឹងត្រូវធ្វើការពិនិត្យ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីឲ្យមកចូលរួមតាមកាលបរិច្ឆេទដែលបានកំណត់នោះ[84]។ ការទាញហេតុផលផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តីដែលក្នុងនោះ សកម្មភាពរបស់តុលាការ និង សកម្មភាពរបស់ភាគីចំពោះការជម្រះក្តីត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍នៅសាលសវនាការ ដែលភាគីទាំងសងខាងអាចមានវត្តមានតាមកាលបរិច្ឆេទ។

### ៥.២.១. ការជម្រះក្តីក្នុងការទាញហេតុផលផ្ទាល់មាត់

ការជម្រះក្តីនៃបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ មិនត្រូវធ្វើជាសាធារណៈឡើយ។ ប៉ុន្តែបើតុលាការយល់ឃើញថាសមរម្យ អាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ អនុញ្ញាតឲ្យជនណាដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍ បានតាមឆន្ទានុសិទ្ធិ[85]។

**ក.**សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់

ការត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដែលបានធ្វើឡើងនៅនីតិវិធីត្រៀបសម្រាប់ការទាញហេតុផល មានលក្ខណៈប្រហាក់ប្រហែងទៅនឹង ការហាត់សមធ្វើការទាញហេតុផលផ្ទាល់មាត់ដែរ តែមិនអាចយកមកជំនួសឲ្យការទាញហេតុផលផ្ទាល់មាត់ពិតប្រាកដបានទេ។

នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋមគូភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលក្នុងនោះត្រូវបញ្ជាក់ឲ្យច្បាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់[86] ពោលគឺត្រូវបញ្ជាក់ពីចំណុចវិវាទឲ្យបានច្បាស់។

**ខ.** ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន

ក្នុងបណ្តឹងលុបចោលអាពាហ៍ពិពាហ៍នេះ មិនមានបញ្ញត្តិហាមឃាត់ការដាក់មធ្យោបាយ តទល់ពីដើមចោទ ឬមធ្យោបាយការពារខ្លួនពីចុងចម្លើយទេ។ ហេតុនេះភាគីអាចធ្វើការនាំយក ឬប្រមូលនូវរាល់ ភស្តុតាងឯកសារពាក់ព័ន្ធទាំងឡាយ ក៏ដូចជាស្នើសុំឲ្យធ្វើការសាកសួរសាក្សីដែលពាក់ព័ន្ធក្នុងបណ្តឹងដើម្បី ឲ្យតុលាការត្រួតពិនិត្យ ។ ក្នុងបណ្តឹងនេះ សិទ្ធិរបស់គូភាគីក្នុងការដាក់នូវមធ្យោបាយតទល់ ឬការពារខ្លួនត្រូវបានផ្តល់នូវលក្ខខណ្ឌកាន់តែប្រសើរ ពោលគឺទោះបីការដាក់មធ្យោបាយតទល់ ឬការពារខ្លួនយឺត ឬមិនត្រូវនឹងពេលសមរម្យដែលបានកំណត់ក្តី តុលាការពុំអាចបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាមទារឲ្យគូភាគីបង្ហាញនូវតម្រុយ ឬ ឯក-

[84] មាត្រា១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[85] មាត្រា១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[86] មាត្រា១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

សារភស្តុតាងជាក់លាក់ដើម្បីទុកលទ្ធភាពបន្ថែមឲ្យតុលាការពិចារណា និងស្រាវជ្រាវបន្ថែម ដើម្បីស្វែងរកការពិតនៃរឿង។

ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីមូលហេតុនៃការដាក់សំណូមពរ ពោលគឺមធ្យោបាយតទល់។ រីឯចុងចោទត្រូវធ្វើសេចក្តីថ្លែងការណ៍ ចំពោះមូលហេតុនៃការឆ្លើយតបរបស់ខ្លួនពោលគឺមធ្យោបាយការពារខ្លួន។ ប៉ុន្តែសិទ្ធិនេះមិនត្រូវបានទទួលស្គាល់ភ្លាមៗនោះទេ គឺដើមចោទត្រូវអះអាងអំពីអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌគតិយុត្តិដែលមានអានុភាពបង្កើតឲ្យមានសិទ្ធិ។

បន្ទាប់ពីគូភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួនហើយ តុលាការត្រូវធ្វើការសម្រេចដោយយោងលើគោលការណ៍ស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងបញ្ចប់ការទាញហេតុផលផ្ទាល់មាត់។

### ៥.២.២. ការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់

ក្រោយពេលស្តាប់ការអះអាងរបស់ភាគី តុលាការពិនិត្យលើសំណុំរឿង ឯកសារពាក់ព័ន្ធដោយផ្អែកលើការស្រាវជ្រាវស្វែងរកការពិត ហើយចេញសាលក្រមលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការ ទាមទាររបស់ដើមចោទដោយបញ្ចប់នូវការទាញហេតុផលផ្ទាល់មាត់ និងចេញសាលក្រមចុងក្រោយ ។ នៅមុនពេលបញ្ចប់តុលាការអាចអនុញ្ញាតឲ្យភាគីទាញហេតុផលចុងក្រោយបានជាឱកាសដែលភាគីនីមួយៗ អាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួនពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ។

ក្រោយពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ហើយបើយល់ថាចាំបាច់តុលាការអាចបើកឲ្យមានការទាញហេតុផលផ្ទាល់មាត់ ដែលត្រូវបានបញ្ចប់ហើយនោះសាជាថ្មីឡើងវិញបានមុនពេលចេញ សាលក្រមចុង-ក្រោយ[87]។ ម៉្យាងទៀតបើនៅក្នុងដំណាក់កាលនីតិវិធីទាញហេតុផល មានលេចចេញនូវអង្គហេតុថ្មីដែលរាំងស្ទះ ឬបង្អាក់ក្នុងការស្វែងរកការពិតដែលចាំបាច់ត្រូវសាកសួរភាគី ឬ ស្រាវជ្រាវបន្ថែម ច្បាប់បានផ្តល់ការអនុញ្ញាតឲ្យតុលាការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលម្តងទៀតបាន បើតុលាការបញ្ចប់ការទាញហេតុផលក្នុងកាលៈទេសៈបែបនេះ អាចផ្ទុយនឹងក្របខ័ណ្ឌយុត្តិធម៌ ប៉ះពាល់ដល់ប្រយោជន៍ជនដែលទទួលនូវអានុភាពនៃសាលក្រម។

## ៦. សេចក្តីសម្រេចលើបណ្តឹង

### ៦.១. សាលក្រមចំពោះមុខ

តុលាការចេញសាលក្រមលើបណ្តឹង ដោយសាលក្រមរបស់តុលាការជាន់ទាប ឬសាលដីការបស់តុលាការជាន់ខ្ពស់ ដែលការណ៍នេះខុសពីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ដែលតុលាការចេញសេចក្តីដោយ

[87] មាត្រា១៨០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ដីកាសម្រេច[88]។ ក្នុងនីតិវិធីបណ្តឹងនេះ តុលាការមិនអនុញ្ញាតឲ្យយកគោលការណ៍នៃការចេញសាលក្រមកំបាំងមុខមកអនុវត្តទេ[89]។ មុនចេញសេចក្តីសម្រេច តុលាការចាំបាច់ត្រូវមានវត្តមានរបស់គូភាគីក្នុងអង្គសវនាការដើម្បីធានា នូវសិទ្ធិក្នុងការបញ្ចេញមតិយោបល់ សំណូមពរក៏ដូចជាដំណាក់កាលចុងក្រោយនៃការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការទាមទាររបស់ខ្លួន ចំពោះមុខចៅក្រមជំនុំជម្រះហើយតុលាការក៏អាចពិចារណាបន្ថែមទៀតទៅលើការអះអាងនោះ ដើម្បីចេញសាលក្រមចុងក្រោយឲ្យមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ដល់ភាគីផ្អែកលើការស្រាវជ្រាវ និងការពិតជាក់ស្តែង។

ជាគោលការណ៍ ចំពោះសេចក្តីសម្រេចនៅក្នុងនីតិវិធីបណ្តឹងនីមួយៗ គឺបានកំណត់ពីការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលជាវិធានធានានូវសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីច្រើនថ្នាក់របស់ភាគី ។ តុលាការជាន់ខ្ពស់អាចនឹងពិនិត្យមើលនូវសេចក្តីសម្រេចរបស់ តុលាការថ្នាក់ក្រោមបានតាមពាក្យបណ្តឹងរបស់ភាគីម្ខាងដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចនោះ បើសេចក្តីសម្រេចតុលាការជាន់ទាបមិនត្រឹមត្រូវ តុលាការជាន់ខ្ពស់អាចធ្វើការកែប្រែ ឬលុបចោលនូវសេចក្តីសម្រេចនោះហើយចេញសេចក្តីសម្រេចថ្មី។

### ៦.២. បណ្តឹងឧបាស្រ័យ

ការប្តឹងឧបាស្រ័យនេះ មានលក្ខណៈដូចនីតិវិធីបណ្តឹងរដ្ឋប្បវេណីដែរ គឺធ្វើតាមរយៈបណ្តឹងឧទ្ធរណ៍ ទៅសាលាឧទ្ធរណ៍ ដើម្បីទទួលចំណាត់ការបន្តលើសេចក្តីវិនិច្ឆ័យរបស់សាលាដំបូង។ បណ្តឹងនេះត្រូវធ្វើក្នុងរយៈពេល ១(មួយ) ខែ[90] គិតពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ទៅកាន់សាលាដំបូងដែលចេញសាលក្រមនោះ។

បើតុលាការចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្តឹងទាមទារឲ្យ លុប-ចោលអាពាហ៍ពិពាហ៍ តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ បើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ[91]។

[88] មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។
[89] មាត្រា១៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។
[90] មាត្រា២៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[91] មាត្រា២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

# ជំពូកទី៣៖

# អានុភាពនៃមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

## ផ្នែកទី១៖ អានុភាពនៃមោឃភាព

អានុភាពនៃមោឃភាព នាំឲ្យគ្មានអាពាហ៍ពិពាហ៍ ហេតុនេះទំនាក់ទំនងប្តី ប្រពន្ធកូន តាមផ្លូវច្បាប់ មិនយកមកអនុវត្តឡើយចំពោះទំនាក់ទំនងភាគីនៃអាពាហ៍ពិពាហ៍ដែលត្រូវបានមោឃភាព។

តើទំនាក់ទំនងប្តីប្រពន្ធ ទ្រព្យសម្បត្តិ កូនត្រូវកំណត់បែបណា ?

តាមក្រមរដ្ឋប្បវេណី ពុំមានបញ្ញត្តិអំពីអានុភាពនៃមោឃភាពចំពោះទំនាក់ទំនងញាតិ ទ្រព្យសម្បត្តិ ឬកូនឡើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អាពាហ៍ពិពាហ៍ដែលមានមូលហេតុមោឃៈ នាំឲ្យភាគីនៃអាពាហ៍-ពិពាហ៍ មិនមែនជាប្តីប្រពន្ធនឹងគ្នាទេ ហេតុនេះ បញ្ញត្តិដែលទាក់ទងនឹងករណីកិច្ចរវាងសហព័ន្ធ កូន សន្តតិកម្ម មិនត្រូវយកអនុវត្តឡើយ។

ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ របស់ភាគីនៃអាពាហ៍ពិពាហ៍ដែលត្រូវបានមោឃៈ ការបែងចែកអាចបកស្រាយ ប្រដូចនឹងករណីលែងលះបាន(ការបកស្រាយនៅប្រទេសជប៉ុន)[92]។

### កថាភាគទី១៖ អានុភាពចំពោះទំនាក់ទំនងញាតិ

ដោយសារតែ អាពាហ៍ពិពាហ៍គ្មានអានុភាព នាំឲ្យពុំមានទំនាក់ទំនងរវាងប្តី និងប្រពន្ធ (មិនមែន សហ-ព័ន្ធ) និង ពុំមានទំនាក់ទំនងញាតិពន្ធ[93] ដែលមានចែងនៅក្នុងចំណុច (ខ) និង (គ) មាត្រា ៩៣៨នៃក្រមរដ្ឋ-ប្បវេណីបច្ចុប្បន្ននេះ។

### កថាភាគទី២៖ អានុភាពចំពោះបុគ្គល

**១. ចំពោះសាមីជន**

អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍ អាចធ្វើឲ្យជីវិតគូមានការផ្លាស់ប្តូរទៅជាជីវិតនៅលីវម្តងទៀត ពោលគឺអាពាហ៍ពិពាហ៍ដែលមានអានុភាព ដែលអ្នកទាំងពីរបានបង្កើតឡើងក្លាយទៅជាឥតបានការ ។ ស្របពេលនោះហើយដែលធ្វើឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានមោឃភាព ប៉ុន្តែក្រោយពីមានការមោឃភាពអាពាហ៍ពិពាហ៍ រវាងសហព័ទ្ធហើយក៏នៅមានបញ្ហាមួយចំនួនតាមមកពីក្រោយ នៃមោឃភាពអាពាហ៍ពិពាហ៍នោះគឺបញ្ហាកូន។

**២. ចំពោះទំនាក់ទំនងនឹងកូន**

---

[92] សិក្ខាសាលាស្តីអំពីមោឃភាព និងការលុបចោល,អ៊ីវ ប៉ូលី, ២០១៨, ស្លាយទី៣៧។

[93] មាត្រា៩៣៨ ចំណុច ខ និង គ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**២.១. ការសន្មតបិតុភាព**

ដោយសារតែ អាពាហ៍ពិពាហ៍ គ្មានអានុភាព ហេតុនេះមិនអាចធ្វើការសម្មតបិតុភាពតាមច្បាប់បានទេ ចំពោះទំនាក់ទនងឪពុក និងកូន។

ក្នុងករណីនេះ តាមច្បាប់ "គ" គឺជាកូនរបស់ "ក" ពីព្រោះ "ក" មានអង្គហេតុសម្រាលកូន (បានបង្កើត "គ")។ ប៉ុន្តែ "ខ" និង "គ" ពុំមានទំនាក់ទំនងញាតិនឹងគ្នាទេ (អ្នកដទៃទោះបីជាធាតុពិត "គ" ជាកូនបង្កើតរបស់ "ខ" ក៏ដោយ) ដោយសារតែ "ក" និង "ខ" ពុំមានចំណងអាពាហ៍ពិពាហ៍នឹងគ្នាហេតុនេះ នាំឲ្យមិនអាចសន្មត បិតុភាពតាមច្បាប់ ។ ទោះបីជា "ខ" និង "គ" គ្មានការសន្មតបិតុភាពតាមច្បាប់ក៏ដោយ "ខ" អាចធ្វើការទទួលស្គាល់កូនបាន ឬ "គ" អាចធ្វើបណ្តឹងទាមទារឲ្យទទួលស្គាល់ ក្នុងករណីនេះទំនាក់ទំនងរវាងឪពុក និងកូនត្រូវបានទទួលស្គាល់តាមច្បាប់[94]។

**២.២. អំណាចមេបា** (**ទោល**)

កូនដែលកើតពីម្តាយដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ អ្នកមានអំណាចមេបាចំពោះកូនជា អនីតិ-ជន គឺម្តាយ[95]។

ក្នុងករណីឪពុក បានទទួលស្គាល់កូន ឪពុកអាចពិភាក្សាជាមួយម្តាយ ដើម្បីខ្លួនក្លាយជាអ្នកមាន អំណាចមេបា ប៉ុន្តែប្រសិនបើម្តាយមិនយល់ព្រមទេ ឬមិនអាចពិភាក្សាគ្នាបានទេ ឪពុកអាចទាមទារទៅតុលាការឲ្យកំណត់ថាខ្លួនជាអ្នកមានអំណាចមេបាចំពោះកូន[96]។

**២.៣. សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន**

ប្រសិនបើ គ្មានការទទួលស្គាល់កូនទេឪពុកពុំមានករណីយកិច្ចទទួលបន្ទុកនូវសោហ៊ុយចាំបាច់ដើម្បី ចិញ្ចឹមកូនទេ ប៉ុន្តែក្នុងករណី ឪពុកបានទទួលស្គាល់កូន ឪពុកមានករណីយកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់ ដើម្បីចិញ្ចឹមកូន[97]។

**៣. ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះភាគពុកិច្ច**

ការទទួលខុសត្រូវដោយសាមគ្គី គឺជាការទទួលខុសត្រូវរួមគ្នារបស់ប្តី ឬ ប្រពន្ធនៅក្នុងគ្រួសារទាំងមូល នៅពេលដែលគ្រួសារមានការខ្វះខាត ឬ មានវិបត្តិណាមួយកើតឡើងចំពោះគ្រួសារនោះ។ បើយោងទៅតាម មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណី ២០០៧ ក៏បានកំណត់ដែល ទាក់ទងទៅនឹងការទទួលខុសត្រូវដោយសាមគ្គី

[94] មាត្រា៩៩៣ និង មាត្រា១០០១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[95] មាត្រា១០៣៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[96] មាត្រា១០៣៨ កថាខណ្ឌទី២ និង ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[97] មាត្រា១០៤០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ភាពចំពោះកាតព្វកិច្ចនេះ។ "ការទទួលខុសត្រូវដោយសាមគ្គីនេះរួមមាន៖

(១)សោហ៊ុយដើម្បីរក្សាជីវៈភាពរួមរស់របស់ប្ដី-ប្រពន្ធ និង សោយហ៊ុយដើម្បីអប់រំ ឬ ការព្យាបាលថែទាំកូន។ (២)កាតព្វកិច្ច និង ករណីកិច្ចផ្សេងៗទៀតដែលប្ដី ឬ ប្រពន្ធទាំងសងខាងបានព្រមព្រៀងលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុលនៅក្នុងកំឡុងពេលរៀបអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីកិច្ចផ្សេងៗទៀតដែលប្ដី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុកដោយមានយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅក្នុងកំឡុងពេលអាពាហ៍ពិពាហ៍។ (៣)សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិ"[98]។ ជាវិធានមួយដើម្បីគ្រប់គ្រងទំនាក់ទំនងខាងក្រៅរវាងប្ដី ឬ ប្រពន្ធ និង ភាគីផ្សេងទៀត។

**កថាភាគទី៣៖ អានុភាពចំពោះទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់**

ក្រមរដ្ឋប្បវេណី ពុំមានបញ្ញត្តិអំពីអានុភាពនៃមោឃភាព អាពាហ៍ពិពាហ៍ទេ ប៉ុន្តែបញ្ហាអាចកើតឡើងប្រសិនបើភាគីនៃអាពាហ៍ពិពាហ៍ដែលត្រូវបានមោឃៈ មានទ្រព្យសម្បត្តិក្នុងអំឡុងពេលនោះ តើត្រូវសម្រេចយ៉ាងម្ដេច?

ករណីនេះ នៅប្រទេសជប៉ុន ចំពោះបញ្ហាទ្រព្យសម្បត្តិ បកស្រាយប្រដូចនឹងករណីលែងលះ ហេតុនេះប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រព័ន្ធតាមច្បាប់និង ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធជាមួយនឹងតតិយជន ត្រូវបានយកមកអនុវត្តផងដែរ ចំពោះមោឃភាពអាពាហ៍ពិពាហ៍។

ប្រសិនបើនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធមិនបានកែសម្រួលអ្វីពិសេសទេ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នឹងត្រូវយកមកអនុវត្ត[99]។

**៣.១. ទ្រព្យសម្បត្តិដោយឡែក**

ជាទ្រព្យសម្បត្តិដោយឡែកដែលស្ថិតក្រោមកម្មសិទ្ធិរបស់សហព័ទ្ធតែម្ខាងដូចជា៖

(១)ទ្រព្យសម្បត្តិដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ (២)ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (៣)ទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិត្រង់ចំណុច(១)ឬ(២)[100]។

ការបែងចែកទ្រព្យសម្បត្តិរួម អាចធ្វើឡើងតាមការព្រមព្រៀងរបស់ភាគី ប៉ុន្តែក្នុងករណីគ្មានការព្រមព្រៀងជាគោលការណ៍ គឺតុលាការសម្រេចឲ្យម្នាក់១ភាគ២នៃទ្រព្យរួម[101]។

---

[98] មាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[99] មាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[100] មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[101] មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ៣.២. ទ្រព្យសម្បត្តិរួម

ជាទ្រព្យសម្បត្តិដែលមានរួមគ្នាហើយសំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាងឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្រៅពីទ្រព្យសម្បត្តិដោយឡែក[102]។

មាត្រានេះបានកំណត់ថាទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ ក្រៅពីទ្រព្យសម្បត្តិដោយឡែកនឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម ។ នៅប្រទេសកម្ពុជាកំពុងប្រើប្រាស់នូវប្រព័ន្ធទ្រព្យសម្បត្តិរួម ប្តីប្រពន្ធដូចដែលបានលើកឡើងនៅខាងលើ។

## ផ្នែកទី១៖ អានុភាពនៃការលុបចោល

ការលុបចោលអាពាហ៍ពិពាហ៍ មិនមានអានុភាពប្រតិសកម្មទេ[103] មានន័យថា ការលុបចោលអាពាហ៍-ពិពាហ៍មិនមានអានុភាពទៅលើអតីតកាល គឺមានអានុភាពរំលាយអាពាហ៍ពិពាហ៍ ឆ្ពោះទៅរកថ្ងៃអនាគតដែលគិតចាប់ពីថ្ងៃដែលតុលាការ បានប្រកាសសាលក្រមលើសេចក្តីសម្រេចលុបចោលអាពាហ៍ពិពាហ៍នោះចូលជាស្ថាពរ។

### កថាភាគទី១៖ អានុភាពចំពោះសំណងការខូចខាត

នៅពេលមានបណ្តឹងកើតឡើង រមែងតែងមានភាគីទទួលរងនូវការខូចខាត ចំពោះបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ក៏មិនខុសគ្នាដែរ ។ ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើទទួលបានទ្រព្យសម្បត្តិដោយការរៀបអាពាហ៍ពិពាហ៍ត្រូវសងទ្រព្យសម្បត្តិនោះត្រឹមកម្រិត នៃផលប្រយោជន៍ទទួលបាន[104]។

ទ្រព្យសម្បត្តិដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍រួមមាន៖

ទ្រព្យសម្បត្តិដែលត្រូវបានធ្វើប្រទានកម្មនៅពេល និងក្នុងពេលរៀបអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម និងអច្ច័យទាន។ ផលប្រយោជន៍ពីការធានារ៉ាប់រងជាអាទិ៍។

ចំពោះភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងផលប្រយោជន៍ ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ ហើយបើភាគីម្ខាងទៀតសុចរិត ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ[105]។ សម្រាប់ផលប្រយោជន៍ទាំងអស់ដែលទទួលដោយការរៀបអាពាហ៍ពិពាហ៍ រួមមានទាំងផលប្រយោជន៍លើទ្រព្យសម្បត្តិទាំងអស់ ដូចជាលំនៅ ថ្លៃចំណាយលើម្ហូប

[102] មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[103] មាត្រា៩៦៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[104] មាត្រា៩៦៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[105] មាត្រា៩៦៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

អាហារ និងការកម្សាន្តជាដើម។

**កថាភាគទី២៖ អានុភាពចំពោះបុគ្គល**

**១. ចំពោះសាមីជន**

អានុភាពនៃសាលក្រមលុបចោលអាពាហ៍ពិពាហ៍ អាចធ្វើឲ្យជីវិតគូមានការផ្លាស់ប្តូរទៅជាជីវិតនៅលីវម្តងទៀតពោលគឺអាពាហ៍ពិពាហ៍ដែលមានអានុភាព ដែលអ្នកទាំងពីរបានបង្កើតឡើងក្លាយទៅជាឥតបានការ។ ស្របពេលនោះផងដែរ ចំណងគតិយុត្តមួយចំនួនក៏ត្រូវបានរលាយដូចជា ករណីកិច្ចដែលប្តីប្រពន្ធត្រូវរួមរស់ជីវភាពមួយគ្នាហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក[106] និងនាមត្រកូលដែល សហព័ទ្ធម្ខាងបានប្តូរទៅប្រើនាមត្រកូលរបស់ សហព័ទ្ធម្ខាងទៀត[107]។ ប៉ុន្តែក៏មានបញ្ហាមួយចំនួនតាមមកពីក្រោយ នៃការរំលាយអាពាហ៍ពិពាហ៍របស់ពួកគេផងដែរ នោះគឺបញ្ហាកូន និង ការបែងចែកទ្រព្យសម្បត្តិនេះឯង។

**២. ចំពោះបុត្តភាព**

នៅពេលដែលមានការរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ប្រាកដជាមានការជះឥទ្ធិពលដល់កូនដោយហេតុឪពុកម្តាយត្រូវបែកបាក់ពោលគឺក្លាយជាអ្នកដទៃ ។ ដូចនេះឪពុកម្តាយដែលត្រូវបានបែកគ្នាត្រូវកំណត់យកភាគីណាម្ខាងជាអ្នកមានអំណាចមេបាតាមការពិភាក្សារវាងភាគីទាំងសងខាង។ ប៉ុន្តែបើការពិភាក្សាមិនបានសម្រេច ឬពុំអាចពិភាក្សាបាន តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ[108]។

ប្រសិនបើអាពាហ៍ពិពាហ៍ត្រូវបានលុបចោលមុនពេលកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ក្រោយពេលកំណើតកូន គេអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាបានតាមការពិភាក្សារបស់ឪពុកម្តាយ។

ចំពោះទារកដែលទើបនឹងកើតគេត្រូវធ្វើការសន្មតបិតុភាពដោយ៖

ទារកនៅក្នុងគត៌ប្រពន្ធដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី។ កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬក្នុងអំឡុងពេល ៣០០(បីរយ)ថ្ងៃ គិតចាប់ពីពេលដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ត្រូវសន្មតថាមានគត៌នៅក្នុងអំឡុងពេលមានអាពាហ៍ពិពាហ៍នោះ។ ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា៩៥០ (អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតនៃក្រមរដ្ឋប្បវេណីបច្ចុប្បន្ន

[106] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[107] មាត្រា៩៦៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[108] មាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និង ទី២ ខាងលើទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្ដីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ[109]។

ការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងពាក់ព័ន្ធនឹងការបីបាច់ថែរក្សាកូន ត្រូវធ្វើឡើងដោយគិតពិចារណាយ៉ាងសំខាន់ទៅលើសុខុមាលភាពរបស់កូន ។ ដូច្នេះតុលាការត្រូវសួរ និង គិតពិចារណានូវយោបល់ក្នុងការសម្រេចសេចក្ដី ដោយមើលទៅតាមអាយុ ឬ ទៅតាមភាពយល់ដឹងរបស់កូននោះ[110]។

**៣. ការមិនផ្តល់អាហារកិច្ច**

អាហារកិច្ចជាករណីកិច្ចចាំបាច់នៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវលុបចោល ពេលដែលឪពុកមានទទួលស្គាល់ថាជាកូនរបស់ខ្លួន នៅក្រោយពេលដែលអាពាហ៍ពិពាហ៍នោះត្រូវបានលុបចោល។ ម្យ៉ាងទៀតកូនក៏ជាជនម្នាក់ដែលទទួលបានអាហារកិច្ចដែរ ។ ជាទូទៅ នៅពេលបណ្ដឹងលុបចោលត្រូវបានសម្រេចសាលក្រមតែងតែភ្ជាប់មកជាមួយនូវការទទួលខុសត្រូវអាហារកិច្ច ដែលនេះគឺជាការគិតគូរអំពីផលប្រយោជន៍របស់កូន និង ជីវភាពរបស់នៅនាពេលខាងមុខ។ ប៉ុន្តែប្រសិនបើ "ករណីសហព័ទ្ធដែលទទួលខុសត្រូវផ្គត់ផ្គង់អាហារកិច្ច មិនគោរពតាមសេចក្ដីសម្រេចស្ថានរបស់តុលាការ ដោយមិនព្រមបង់រយៈពេល ២(ពីរ) ខែយ៉ាងតិចនូវអាហារកិច្ចដល់កូនជាអនីតិជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០ (ពីរលាន) រៀល "[111]។

**កថាភាគទី៣៖ អានុភាពចំពោះទ្រព្យសម្បត្តិរបស់សហព័ទ្ធ**

ក្រៅពីបញ្ហាសំណងការខូចខាត បញ្ហាចំពោះសាមីខ្លួន និង អំណាចមេបាលើបុគ្គភាពមានបញ្ហាចោទមួយទៀតដែលអាចក្លាយជា ផលវិបាកក្រោយពេលមានការលុបចោលអាពាហ៍ពិពាហ៍ កើតឡើងគឺទ្រព្យសម្បត្តិ។ អាជ្ញាយុកាលនៃ ការលុបចោលអាពាហ៍ពិពាហ៍ធ្វើឲ្យកើតមាននូវសិទ្ធិ និង កាតព្វកិច្ចជាច្រើនរវាង សហព័ទ្ធដូចជាការទទួលបានទ្រព្យតាមរយៈកិច្ចមុជា និង កិច្ចមូលា ដែលកើតមានក្នុងពេលអាពាហ៍ពិពាហ៍ ត្រូវបានលុប-ចោល។

**១. ប្រព័ន្ធទ្រព្យសម្បត្តិតាមវិធាននៃកិច្ចសន្យា**

កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និង ដើម្បីបញ្ជាក់ឲ្យច្បាស់អំពីទំនាក់ទំនងសិទ្ធិ និង ករណីកិច្ចរបស់ប្ដីប្រពន្ធ ពោលគឺសហព័ទ្ធទាំងសងខាងត្រូវបានផ្តល់លទ្ធភាព ដែលអាចកំណត់ដោយខ្លួនឯងនូវ សមាសភាពនៃទ្រព្យរួម វិធាននៃការគ្រប់គ្រង ព្រមទាំងការ

---

[109] មាត្រា៩៨៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[110] មាត្រា២២ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០។
[111] មាត្រា៣២៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០។

ជម្រះបញ្ជី និងការបែងចែករបបមាតិកភណ្ឌគ្រួសារ។ ប៉ុន្តែបញ្ញត្តិនេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ[112]។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ហើយត្រូវចុះបញ្ជីឲ្យបានត្រឹមត្រូវនៅក្រសួងយុត្តិធម៌ ដើម្បីអាចយកទៅតតាំង ជាមួយនឹងតតិយជនបាន[113]។ ម្យ៉ាងទៀតការជ្រើសរើសយកប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ អាចផ្តល់ភាពងាយស្រួលដល់ ស្ថាប័ន-តុលាការព្រមទាំងជៀសវាងនូវវិវាទវែងឆ្ងាយរវាងគូភាគី ពេលបែងចែកទ្រព្យសម្បត្តិក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានរំលាយដោយភាគីគ្រាន់តែអនុវត្តតាមបញ្ញត្តិដែលបានកំណត់ក្នុងកិច្ចសន្យានោះជាការសម្រេច។

**២. ប្រព័ន្ធទ្រព្យសម្បត្តិកំណត់តាមច្បាប់**

បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច បើសហព័ទ្ធទាំងសងខាងមិនបានសម្តែងឆន្ទៈថានឹង ជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងសម្បត្តិណាមួយទេ នោះគេសន្មតថាពួកគេរើសយកប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ដោយស្វ័យប្រវត្តិ។ ក្នុងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នេះបាន បែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរប្រភេទគឺ៖ ទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក។

**២.១. ទ្រព្យសម្បត្តិដោយឡែក**

ទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យដែលសហព័ទ្ធម្ខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ទ្រព្យដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និង ទ្រព្យដែលជាតម្លៃតបដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត[114] ។ ជាការពិតណាស់នៅពេលដែលជីវភាពអាពាហ៍ពិពាហ៍បន្តកាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបានអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់ថា តើជាទ្រព្យផ្ទាល់ខ្លួន ឬ ជាទ្រព្យរួមដែលបណ្តាលឲ្យក្លាយទៅជាវិវាទនៅពេលមានការបែងចែកទ្រព្យកើតឡើង។ ជាដំណោះស្រាយភាគីគប្បីធ្វើជាបញ្ជីទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់រវាងទ្រព្យដោយឡែក និង ទ្រព្យរួម។ ទ្រព្យសម្បត្តិដោយឡែកនេះ មិនមែនជាកម្មវត្ថុនៃការបែងចែកនៅពេលដែលភាគីមានការបែកបាក់គ្នានោះទេព្រោះទ្រព្យប្រភេទនេះស្ថិតក្រោមការគ្រប់គ្រងរបស់សហព័ទ្ធតែម្ខាងដែលជាម្ចាស់កម្មសិទ្ធិប៉ុណ្ណោះ។ហេតុនេះក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោលភាគីមិនអាចប្តឹងទាមទារឲ្យបែងចែក ទ្រព្យសម្បត្តិដោយ-ឡែករបស់ភាគីម្ខាងទៀតបានឡើយ។

**២.២. ទ្រព្យសម្បត្តិរួម**

[112] មាត្រា៩៦៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[113] មាត្រា៩៧០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[114] មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទ្រព្យសម្បត្តិរួម ជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ថាជាទ្រព្យសម្បត្តិដោយឡែក[115]។ សហព័ទ្ធទាំងសងខាងមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម តែការប្រើប្រាស់ទ្រព្យនោះ ត្រូវបានស្ថិតក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព[116]។ ការចាត់ចែងទ្រព្យសម្បត្តិរួមដោយ យកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយគ្មានការយល់ព្រមពីសហព័ទ្ធទាំងសងខាង មិនត្រូវបានអនុញ្ញាតឡើយ[117]។ នៅពេលមានការបែកបាក់កើតឡើង ទ្រព្យរួមនេះត្រូវធ្វើការបែងចែកដោយយុត្តិធម៌ ដោយផ្អែកតាមការពិភាក្សាព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង។ ករណីមានវិវាទក្នុងការបែងចែក ច្បាប់បានបញ្ញត្តិឲ្យចែកទ្រព្យសម្បត្តិនោះជាពីរភាគស្មើៗគ្នាទៅឲ្យសហព័ទ្ធនីមួយៗ។ ប៉ុន្តែបើមានការកើតទុក្ខមិនសុខចិត្តចំពោះការសម្រេចនោះ ភាគីម្ខាងអាចលើកពីស្ថានភាពផ្សេងទៅកាន់តុលាការ ដើម្បីធ្វើការពិចារណាដូចជាទំហំនៃការបរិច្ចាគ លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ ព្រមទាំងផលប្រយោជន៍កូនជាដើម។ គេហកិច្ចត្រូវចាត់ទុកមានតម្លៃស្មើនឹង ការងារដែលធ្វើនៅក្រៅផ្ទះដែរ[118]។

[115] មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[116] មាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[117] មាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[118] មាត្រា៩៨០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទ " មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍" នេះមកសង្កេតឃើញថា ទោះជាមានភាពខុសគ្នារវាងមូលហេតុដែលនាំឲ្យកើតមាននូវបណ្តឹងទាមទារឲ្យ មោឃ-ភាពបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ និងបណ្តឹងលែងលះយ៉ាងណាក្តី ប៉ុន្តែក៏មានចំណុច ប្រសព្វ រួមនូវលទ្ធផលនៃការផ្តាច់ចំណងគតិយុត្តរវាង សហព័ទ្ធទាំងពីរដូចគ្នាគឺ ធ្វើឲ្យជីវិតគ្រួសារ ដែលធ្លាប់តែរួមរស់ជាមួយគ្នាប្រែក្លាយជាអ្នកដទៃ។ ការចែកផ្លូវគ្នារវាង អ្នកទាំងពីរមិនត្រឹមតែជះឥទ្ធិពលចំពោះខ្លួនគេប៉ុណ្ណោះទេតែក៏អាចប៉ះពាល់ដល់អារម្មណ៍កូនដែលធ្លាប់តែរស់នៅជាមួយនឹងឪពុកម្តាយ បែរជាត្រូវឈរមើលលោក ទាំងពីរបែកគ្នាជាងនេះទៅទៀតនោះគឺ ត្រូវជ្រើសរើស ឬ បាត់បង់ម្នាក់ក្នុងចំណោមអ្នកមានគុណទាំងពីរតាមសេចក្តីសម្រេចរបស់តុលាការ។ មិនតែប៉ុណ្ណោះរវាងសមាជិកគ្រួសារទាំងពីរ អាចនឹងមើលមុខគ្នាមិនចំពោលគឺ បាត់បង់ទាំងភាពជាសាច់ញាតិនឹងគ្នា និង មិត្តភាព ហើយអាចនឹងឈានដល់ស្ថានភាពដែលក្លាយជាសត្រូវ នឹងគ្នាក៏មាន។ លើសពីនេះការបែងចែកទ្រព្យសម្បត្តិក៏នឹងក្លាយជាបញ្ហាដែលនាំឲ្យមានការថ្នាំងថ្នាក់ នៅពេលដែលមិនមានការព្រមព្រៀងមួយជាក់លាក់ដែលអាចនឹងក្លាយទៅជាជម្លោះផងដែរ។

ជាភ័ព្វសំណាងដែលប្រទេសកម្ពុជាមាននូវច្បាប់មួយចំនួនដូចជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម។ ដែលក្នុងនោះមានបញ្ញត្តិអំពី មូលហេតុដែលអាចនិយាយបានថាវិធាននៃការការពារ មិនឲ្យមានបណ្តឹងមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍នេះកើតឡើង ។ ក៏ប៉ុន្តែបើបញ្ញត្តិជាមូលហេតុខាងលើត្រូវបានគេបំពាននោះក៏មានបញ្ញត្តិបន្តដែលជានីតិវិធី ឬ ដំណោះស្រាយបញ្ហាដែលកើតមានជាបន្តបន្ទាប់ផងដែរដូចជា ការផ្តាច់ចំណងគតិ-យុត្ត បញ្ហាបុត្តភាព និងទ្រព្យសម្បត្តិដែលត្រូវធ្វើការដោះស្រាយក្រោយមានការបែកបាក់រវាងអ្នកទាំងពីរ។

ទោះជាយ៉ាងណា គ្មានអ្វីដែលល្អឥតខ្ចោះនៅលើលោកនេះទេ ដូចគ្នាទៅនឹងច្បាប់នីមួយៗផងដែរ គឺតែងមានចន្លោះខ្វះខាត ដែលនាំឲ្យមានភាពស្មុគស្មាញ ដល់តុលាការក្នុងការដោះស្រាយរឿងក្តី ក៏ដូចជាខ្វះខាតនូវធនធានមនុស្សក្នុងវិស័យច្បាប់ ដែលអាចជាមូលហេតុមួយនាំឲ្យមានការយឺតយ៉ាវក្នុងដំណើរការបណ្តឹង។ ហេតុនេះ សិស្សនិស្សិត ក៏ដូចជាប្រជាពលរដ្ឋគប្បីសិក្សាយល់ដឹងនូវបញ្ញត្តិច្បាប់ឲ្យបានច្រើន ដែលអាចការពារខ្លួនអ្នកដទៃ ក៏ដូចជាសង្គមឲ្យជៀសផុតពីភាពរឹកររដែលកើតពីការប្រព្រឹត្តផ្ទុយនឹងច្បាប់ប្រទេស មិនតែប៉ុណ្ណោះក៏អាចជួយឲ្យប្រទេសរីកចម្រើនមួយកម្រិតផងដែរ។

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវកន្លងមក បានបង្ហាញឃើញថាការកើតមានឡើងនៃបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ និង បណ្តឹងទាមទារឲ្យមោឃភាព នៅមានចំនួនតិចតួចនៅឡើយបើធៀបទៅនឹងបណ្តឹងលែងលះ។ បើទោះជាមានភាពខុសគ្នាទៅលើចំណុចមួយចំនួនក្នុងដំណើរការនីតិវិធីរវាងបណ្តឹង ទាំងពីរខាងលើក៏ដោយ តែអានុភាពនៃបណ្តឹងទាំងនេះមានគោលដៅនិងលទ្ធផលដូចគ្នា។ ដូចដែលបាន បកស្រាយយ៉ាងលម្អិតក្នុងចំណុចនីមួយៗខាងលើពោលគឺ មានការបែកបាក់ គ្រួសារឪពុកម្តាយនិងកូន ព្រមទាំងមានការបែងចែកនូវទ្រព្យសម្បត្តិផងដែរ។ មិនតែប៉ុណ្ណោះអាចធ្វើឲ្យខាតបង់ពេលវេលា និងថវិកាទៀតផង។

ការកើតឡើងនៃបណ្តឹងទាមទារឲ្យមោឃភាពបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍មានចំនួនមិនច្រើនមិនមានន័យថា ករណីបំពានមូលហេតុដែលនាំឲ្យមានការមោឃភាព ឬការលុបចោលអាពាហ៍ពិពាហ៍មិនកើតមានឡើងទេ។ ក្នុងសង្គមជាក់ស្តែងការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋមានកម្រិតនៅឡើយ ជាហេតុដែលនាំឲ្យ ប្រជាពលរដ្ឋទាំងនោះមិនបានដឹងថាករណីដែលបាននិងកំពុងជួបប្រទះនេះជាមូលហេតុមួយក្នុងចំណោមលក្ខខណ្ឌ ដែលអាចប្តឹងមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍បាន។ ដើម្បីចៀសវាងបញ្ហាដែលកើតឡើង មុនពេលរៀបអាពាហ៍ពិពាហ៍អនាគតគូស្វាមីភរិយា គប្បីសិក្សាអំពីលក្ខខណ្ឌឲ្យបានច្បាស់លាស់ ដែលវាមិនត្រឹមតែចៀសផុតពីបញ្ហាដែលបានរៀបរាប់ខាងលើនោះទេថែមទាំងជួយ សម្រាលបន្ទុក និងភាពស្មុគស្មាញដល់តុលាការផងដែរ។

លើសពីនេះ ការយល់ដឹងនូវច្បាប់របស់ប្រទេសមិនត្រឹមតែ អាចជួយខ្លួនឯងប៉ុណ្ណោះទេតែក៏អាចជាផ្នែកមួយដែលជួយអភិវឌ្ឍន៍សង្គមជាតិឲ្យរីកចម្រើនផងដែរ។ ហេតុនេះមិនថាសិស្សនិស្សិត ប្រជាពលរដ្ឋ គប្បីសិក្សាស្វែងយល់បន្ថែមទៅលើផ្នែកច្បាប់នានា ឲ្យបានច្បាប់លាស់ដើម្បីជាសសរទ្រូងរបស់ប្រទេស។ ស្របពេលជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលគប្បីធ្វើការផ្សព្វផ្សាយបន្ថែមទៅលើផ្នែកច្បាប់តាមបណ្តាញសង្គម ឬ ប្រព័ន្ធផ្សេងៗ ដូចជា ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី ឬបណ្តាញសង្គមហ្វេសប៊ុក (Facebook), តេលាក្រាម (Telegram) ឬចាត់តាំងមន្ត្រីដែលមានជំនាញចុះទៅបង្រៀនដល់មូលដ្ឋានដាច់ស្រយាល ដែលអ្នកទាំងនោះខ្វះខាតការយល់ដឹងផ្នែកច្បាប់ និងដើម្បីជាជំនួយដល់ប្រជាពលរដ្ឋ ដែលមិនមានឱកាសបានរៀនសូត្រ ឲ្យបានយល់ដឹងបន្ថែមដើម្បីជាកម្លាំងមួយទៀតក្នុងការអភិវឌ្ឍន៍ប្រទេស និងផ្តល់សន្តិភាពជូនជាតិ។

# គន្ថនិទ្ទេស


## ១. ច្បាប់

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៥ គន្ថីទី៧* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០)។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ២០១០។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ៥៦ក្រ, ២០ កក្កដា ១៩៨៩។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/១០៩៦/៣០, ០៩ តុលា ១៩៩៦។

ច្បាប់ស្តីពី ឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ០១ កញ្ញា ២០០៦។

ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ៨ មិថុនា ២០១០។

## ២. អនុក្រឹត្យ

អនុក្រឹត្យស្តីពី អគ្រានុកូលដ្ឋាន, លេខ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០។

## ៣. សៀវភៅ

ឥន ឌឿន, *នីតិគ្រួសារ និងអាពាហ៍ពិពាហ៍.* ភ្នំពេញ, ២០១៣។

ស្រី វណ្ណធី, *នីតិបេតិកភណ្ឌ និងគ្រួសារ.* ភ្នំពេញ, ២០១២។

## ៤. សិក្ខាសាលា

អ៊ីវ ប៉ូលី, *សិក្ខាសាលាស្តីអំពីមោឃភាព និងការលុបចោល.* ភ្នំពេញ, ២០១៨។

## ៥. សន្ទានុក្រម

ក្រសួងយុត្តិធម៌, *សន្ទានុក្រមរដ្ឋប្បវេណី.* ភ្នំពេញ, ២០០៧។

សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រម.* ភ្នំពេញ, ១៩៦៧។

## ៦. គេហទំព័រ

វិគីភីឌា, *Km.wikipedia.org.com.* ភ្នំពេញ, ០៣ មិថុនា ២០១៥។